**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 18 / 01 / 2013
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សេចក្តីសន្និដ្ឋានបន្ថែមពាក់ព័ន្ធនឹងច្បាប់ជាធរមាន

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

ព្រុំ ផល្លា

Victor KOPPE
Joshua ROSENSWEIG
Sofie HOGESTOL
Renee DE GEUS

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តី នួន ជា ("ក្រុមមេធាវីការពារក្តី") តាមរយៈឯកសារនេះ សូមដាក់សេចក្តីសន្និដ្ឋានបឋម ("សេចក្តីសន្និដ្ឋាន") ពាក់ព័ន្ធនឹងធាតុផ្សំនីត្យានុកូលនៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១៖

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីដាក់ផ្នែកផ្សេងៗនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹង "ច្បាប់ជាធរមាន" មិនឲ្យហួសពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២[1]។ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានគូសបញ្ជាក់ថាសេចក្តីសន្និដ្ឋានទាំងអស់នេះត្រូវលើកឡើងឲ្យបានច្បាស់លាស់អំពី "ធាតុផ្សំនីត្យានុកូលនៃបទល្មើសទាំងអស់ និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១[2]។ នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះបានធ្វើការពន្យល់ថា ភាគីនានានឹងមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានបន្ថែមទៀត ពាក់ព័ន្ធនឹងច្បាប់ជាធរមាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលមុនសវនាការ ("សារណាបញ្ចប់ការពិភាក្សាដេញដោល")[3]។ នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះបានយល់ព្រមតាមផ្នែកមួយនៃសំណើរបស់ក្រុមមេធាវីការពារក្តី ដែលសុំពន្យារពេលរហូតដល់ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣[4]។

2. ហេតុនេះ ក្រុមមេធាវីការពារក្តីសូមដាក់សេចក្តីសន្និដ្ឋាននេះពាក់ព័ន្ធនឹងផ្នែកសំខាន់ៗនៃធាតុផ្សំនៃ

---

[1] ឯកសារ លេខ E-163/5 "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ERN 00850036-00850037 កថាខណ្ឌ ៤។

[2] ឯកសារ លេខ E-163/5/4 "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ការជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តី-សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល" ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ERN 00863627-00863628 ទំព័រ ២។

[3] ឯកសារ លេខ E-163/5/6 "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្តីបញ្ជាក់ស្តីពីការដាក់សារណាពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ ERN 00866790-00866790 កថាខណ្ឌ ៣។

[4] ឯកសារ លេខ E-163/5/7 "ការទំនាក់ទំនងគ្នាតាមសារអេឡិចត្រូនិកពាក់ព័ន្ធនឹងការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ នួន ជា សុំពន្យារពេលដាក់សារណាពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ ERN 00869845-00869848 ទំព័រ ២។

បទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១។ ក្រុមមេធាវីការពារក្ដីសូមរក្សាសិទ្ធិក្នុងការបរិយាយអំពីគោលជំហរដែលបានបញ្ជាក់នៅក្នុងពេលនេះ និងផ្ដល់ទឡ្ហីករណ៍បន្ថែមទាក់ទិនទៅនឹងច្បាប់ជាធរមាននៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការ ពិភាក្សាដេញដោល។

## II. យុត្តាធិការរបស់ អ.វ.ត.ក មានលក្ខណៈមិនស៊ីសង្វាក់គ្នាជាមួយ នឹងគោលការណ៍នីត្យានុកូលភាពក្នុងប្រទេសនេះ

3. ដូចដែលក្រុមមេធាវីការពារក្ដីបានលើកឡើងកាលពីមុនដែរ[5] យុត្តាធិការរបស់ អ.វ.ត.ក មានលក្ខណៈមិនស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពក្នុងប្រទេសនោះទេ។ តុលាការ (ដូចជា អ.វ.ត.ក) ដែលត្រូវបានបង្កើតឡើងនៅក្នុងយុត្តាធិការនៃរដ្ឋមួយ អាចអនុវត្តបាន ច្បាប់ព្រហ្មទណ្ឌជាសារធាតុ *តែប៉ុណ្ណោះ* ពីព្រោះតុលាការនេះស្ថិតនៅក្នុងរដ្ឋនោះ នៅពេលដែលបទល្មើសត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត។ មិនថាបទល្មើសទាំងឡាយដែលស្ថិតនៅក្នុង យុត្តាធិការលើបទល្មើសរបស់ អ.វ.ត.ក ដែលមានចែងពីមាត្រា ៤ ដល់ ៨ នៃច្បាប់ អ.វ.ត.ក ត្រូវបានកំណត់និយមន័យថាយ៉ាងម៉េចនៅក្នុងច្បាប់ *អន្តរជាតិ* នោះទេ គ្មានអ្វីដែលត្រូវតវ៉ាបានទេថា បទល្មើសទាំងនោះមិនមានចែងនៅក្នុងច្បាប់*ក្នុងប្រទេស* ឡើយ។ ដូច្នេះ និយមន័យក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិស្ដីពីបទល្មើស និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ *គ្មានការពាក់ព័ន្ធទេ*។ ក្រុមមេធាវីការពារក្ដីសូមបញ្ចូល តាមរយៈការទាញយោង និងសូមលើកឡើងវិញម្ដងទៀតអំពីទឡ្ហីករណ៍កាលពីមុនៗរបស់ខ្លួន ទាក់ ទងនឹងបញ្ហានោះ[6]។

## III. ច្បាប់អន្តរជាតិជាធរមាន

4. ម្យ៉ាងទៀត និយមន័យនៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានជ្រើសរើស ដូចដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងពេលវេលាពាក់ព័ន្ធនោះ មានដូចខាងក្រោម។

---

[5] ឯកសារ លេខ E51/3 "អញ្ញត្រកម្មរួមបញ្ចូលគ្នា" ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00648279-00648310 កថាខណ្ឌ ៤២ ដល់ ៤៤។

[6] ឯកសារ លេខ E51/3 "អញ្ញត្រកម្មរួមបញ្ចូលគ្នា" ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00648279-00648310 កថាខណ្ឌ ៤២ ដល់ ៤៤។

## ក. ការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ

5. វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើង នៅពេលដែលវិធាននេះទទួលបានការគាំទ្រពីការអនុវត្តជាក់ស្តែងរបស់រដ្ឋផង និងពី *ទស្សនៈច្បាប់* (*opinio juris*)ផង។ ការអនុវត្តជាក់ស្តែងរបស់រដ្ឋត្រូវតែ "មានលក្ខណៈទូលំទូលាយ និងដូចៗគ្នា"[7] និងកើតចេញមកពី "កាតព្វកិច្ចតាមផ្លូវច្បាប់ មិនមែនដោយសារគារវកិច្ច ភាពយុត្តិធម៌ និងសីលធម៌ទេ"[8]។ ភ័ស្តុតាងនៃ *ទស្សនៈច្បាប់* រួមមាន សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលជាផ្លូវការ សេចក្តីថ្លែងការណ៍របស់អង្គការអន្តរជាតិ និងសន្ធិសញ្ញាស្តីពីការបង្កើតច្បាប់នានា[9]។ បន្ថែមពីលើនេះ វិសាលភាពនៃការអនុវត្តជាក់ស្តែងរបស់រដ្ឋ បង្ហាញអំពី *ទស្សនៈច្បាប់*[10]។

## ខ. អំពើអមនុស្សធម៌ផ្សេងៗទៀតតាមរយៈការជម្លៀសដោយបង្ខំ

6. យោងតាមដីកាដំណោះស្រាយ *ធាតុផ្សំសត្យានុម័ត* (*actus reus*) នៃអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការជម្លៀសដោយបង្ខំ មានដូចខាងក្រោម: (i) ជនរងគ្រោះបានទទួលរងការឈឺចាប់ធ្ងន់ធ្ងរផ្នែករូបកាយ ឬផ្លូវចិត្ត ឬការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលមានកម្រិតធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងការរងគ្រោះនៃអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត (ii) ជន

---

[7] រឿងក្តី ខ្ពង់រាបសមុទ្រខាងជើង (ប្រទេសអាល្លឺម៉ង់ ទល់នឹង ប្រទេសដាណឺម៉ាក និងប្រទេសអាល្លឺម៉ង់ ទល់នឹង ប្រទេសហុល្លង់) សាលក្រម តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ កថាខណ្ឌ ៧៤ ("សាលក្រមខ្ពង់រាបសមុទ្រខាងជើង")។

[8] Ian Brownlie "គោលការណ៍នៃច្បាប់អន្តរជាតិសាធារណៈ" សាព័ត៌មានសាកលវិទ្យាល័យ Oxford បោះពុម្ពលើកទី ៦ ទំព័រ ៨។

[9] សាលក្រមខ្ពង់រាបសមុទ្រខាងជើង កថាខណ្ឌ ៤៧ ដល់ ៧២។

[10] សាលក្រមខ្ពង់រាបសមុទ្រខាងជើង កថាខណ្ឌ ៧៧។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ពាក់ព័ន្ធនឹងការបង្កើតច្បាប់ទំនៀមទម្លាប់ស្តីពីការទទួលខុសត្រូវឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល គ្រាន់តែ "កង្វះនៃការចោទប្រកាន់មិនអាចយកជាមូលដ្ឋានក្នុងការបង្ហាញឲ្យឃើញស្វ័យប្រវត្តិថាគ្មានអត្ថិភាពនៃការអនុវត្តរបស់រដ្ឋជាក់ស្តែងឡើយ"។ *សូមមើល ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្កេកអ៊ាវ* ហៅ *ឌុច* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក ឯកសារ លេខ F-28 "សាលដីកាលើបណ្តឹងសាទុក្ខ" ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ERN 00797698-00798047 ("សាលដីកាឌុច") កថាខណ្ឌ ៩៣។ ទាក់ទងទៅនឹង ការជម្លៀសដោយបង្ខំ ការវិភាគដែលត្រូវបានបង្ហាញនៅពេលនេះ មិនផ្អែកទាល់តែសោះលើ "កង្វះនៃការចោទប្រកាន់តែមួយមុខ" នោះទេ។ ផ្ទុយទៅវិញ វាផ្អែកលើ (i) ការខកខានរបស់រដ្ឋក្នុងការ *ហាមឃាត់*មិនឲ្យមានការប្រព្រឹត្តដែលពាក់ព័ន្ធ ទោះបីរហូតដល់ចុងឆ្នាំ ១៩៧៤ ក៏ដោយ នៅក្នុងទម្រង់មិនចងកាតព្វកិច្ច និង (ii) ការអនុម័តជា *វិជ្ជមាន និងដោយចាប់អារម្មណ៍* របស់រដ្ឋ និងអង្គការអន្តរជាតិនានា។

រងគ្រោះត្រូវបានបង្ខំឱ្យចាកចេញពីទីលំនៅស្របច្បាប់របស់ខ្លួន (iii) ដោយគ្មានមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ[11]។ ទាក់ទងទៅនឹងធាតុផ្សំទីបី ក.ស.ច.ស បានលើកឡើងថា មូលដ្ឋានទាំងនេះ ពិតជា រួមបញ្ចូលទាំង (i) សន្តិសុខរបស់ប្រជាពលរដ្ឋ និង (ii) ស្ថានភាពចាំបាច់ផ្នែកយោធា និង *អាច* រួមទាំងតម្រូវការម្ហូបអាហារជាបន្ទាន់ និង/ឬ ការថែទាំផ្នែកវេជ្ជសាស្ត្រ[12]។ ក.ស.ច.ស ក៏បានលើកឡើងផងដែរថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំមានភាពសមស្រប តែនៅពេលដែលប្រជាជនត្រូវបានផ្តល់នូវឱកាសឲ្យវិលត្រលប់ទៅ "ផ្ទះ" វិញប៉ុណ្ណោះ[13]។

7. សម្រាប់សំអាងហេតុដែលមានបន្តបន្ទាប់ទៀត និយមន័យនេះពឹងផ្អែកខ្លាំងលើប្រភពនានានៃច្បាប់ដែលនៅចន្លោះខែ មេសា ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧[14] ប្រភពច្បាប់ទាំងនេះមិនអាចអនុវត្តបានចំពោះការផ្លាស់ទីលំនៅប្រជាជនដែលអនុវត្តដោយរដ្ឋអធិបតេយ្យមួយ នៅក្នុងដែនដីរបស់ខ្លួនបានទេ។ និយមន័យត្រឹមត្រូវរឹតតែត្រូវបានកម្រិតខ្លាំងថែមទៀត និងពឹងផ្អែកខ្លាំងផងដែរទៅលើកាលៈទេសៈទាំងឡាយ ព្រមទាំងបរិបទជុំវិញការជម្លៀស។

### i. **អំពើអមនុស្សធម៌មួយផ្សេងទៀត និងគោលការណ៍នីត្យានុកូលភាព**

8. ភាពពុំច្បាស់លាស់នៅក្នុងឃ្លា "អំពើអមនុស្សធម៌ផ្សេងៗទៀត" បានបណ្តាលឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងលើបញ្ហានៃការមិនគោរពតាមគោលការណ៍នីត្យានុកូលភាព[15]។ ឃ្លានេះមានភាពជាក់លាក់ *ខ្លះ* តាមរយៈគោលការណ៍នៃ*អំពើដូចគ្នា* (*esjudem generis*) ដែលតាមគោលការណ៍នេះ អំពើទាំងឡាយណាដែលមានលក្ខណៈ ឬស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្ម

---

[11] ឯកសារ លេខ D427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ") ERN 00604508-00605246 កថាខណ្ឌ ១៤៥៩។

[12] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៥៨ និង ១៤៦១។

[13] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៦៤។

[14] ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ២ ត្រូវបានលើកឡើងថាបានបន្តរហូតដល់ពេលមួយនៅក្នុងឆ្នាំ ១៩៧៧ ដែលជាចុងបញ្ចប់នៃយុត្តាធិការតាមពេលវេលារបស់តុលាការនេះ នៅក្នុងសំណុំរឿង ០០២/០១។ *សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣។

[15] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Kupreskic និងជនផ្សេងទៀត* IT-95-16-T "សាលក្រម" ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ("សាលក្រម *Kupreskic*") កថាខណ្ឌ ៥៦៣។

ប្រឆាំងមនុស្សជាតិដូចដែលមានចែងនៅក្នុងច្បាប់[16]។ តុលាការបានផ្តល់និយមន័យបន្ថែមលើឃ្លានេះដោយបានភ្ជាប់វាទៅនឹងសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាទូទៅ ក្នុងនោះរួមទាំងសិទ្ធិដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងសន្ធិសញ្ញានានាដែលត្រូវបានផ្តល់សច្ចាប័នយ៉ាងទូលំទូលាយ[17]។

9. នៅក្នុងតុលាការនេះ ដោយពិចារណាលើរយៈពេលដែលកន្លងផុតយូរមកហើយបើគិតចាប់តាំងពីចុងបញ្ចប់នៃយុត្តាធិការតាមពេលវេលា អង្គជំនុំជម្រះត្រូវមានការប្រុងប្រយ័ត្ននៅក្នុងការវាយតម្លៃរបស់ខ្លួនលើការផ្លាស់ប្តូរជំហរចំពោះទង្វើដែលត្រូវបានចោទប្រកាន់ថាជាអំពើអមនុស្សធម៌ផ្សេងមួយទៀត។ គោលការណ៍នីត្យានុកូលភាពតម្រូវថា *ក្នុងចំណោមនោះ* ជនជាប់ចោទត្រូវមានលទ្ធភាពប្រមើលមើលឃើញថា ខ្លួនអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសកម្មភាពរបស់ខ្លួន ប្រសិនបើខ្លួនត្រូវបានចាប់ខ្លួន[18]។ មានន័យថា ទង្វើមួយអាចត្រូវបានចាត់ទុកជា អំពើអមនុស្សធម៌ផ្សេងមួយទៀត បានតែក្នុងករណីដែលទង្វើនេះ ត្រូវបានយល់ឃើញថា *នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង* ជាការរំលោភលើច្បាប់អន្តរជាតិ ដែលមានស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចដែលមានចែងនៅក្នុងច្បាប់តែប៉ុណ្ណោះ។ ការបញ្ជាក់ផ្សេងៗថា ទង្វើណាមួយមិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធ បង្ហាញថា ទង្វើនេះមិនត្រូវបានប្រមើលមើលឃើញទេ ហេតុដូច្នេះ វាពុំបណ្តាលឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ[19]។

---

[16] លក្ខន្តិកៈនៃតុលាការ ICC មាត្រា ៧(១)(ត)។ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៤៩។

[17] សាលក្រម *Kupreskic* កថាខណ្ឌ ៥៦៦។

[18] រឿងក្តី*រដ្ឋអាជ្ញា ទល់នឹង Milutinovic និងជនផ្សេងទៀត* IT-99-37-AR72 "សេចក្តីសម្រេចលើញត្តិរបស់ Dragoljub Ojdanic តវ៉ាលើយុត្តាធិការ៖ សហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០០៣ កថាខណ្ឌ ២១។ សាលដីកាឌុច កថាខណ្ឌ ៩៦។

[19] អង្គបុរេជំនុំជម្រះបានសម្រេចថា អំពើអមនុស្សធម៌ផ្សេងទៀតគឺជាបទល្មើសដោយខ្លួនវាតែម្តង ហេតុដូច្នេះ វាពុំចាំបាច់បង្ហាញឱ្យឃើញថាវាជាអំពើល្មើសដាច់ដោយឡែកដែលត្រូវបានចោទប្រកាន់នោះទេ។ *សូមមើល* ឯកសារលេខ D-427/1/30 "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ERN 00661785-00661994 កថាខណ្ឌ ៣៧៨។ បើទោះជាសន្មតថា សេចក្តីសន្និដ្ឋាននេះត្រឹមត្រូវក៏ដោយ ការខកខាននៅក្នុងពេលវេលាដែលពាក់ព័ន្ធនៅក្នុងការកំណត់លក្ខណៈ ឬ ចោទប្រកាន់អំពើជាក់លាក់ណាមួយថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងទំនងជាបង្ហាញថាអំពើនោះគឺមិនមែនជា*ឧក្រិដ្ឋកម្មមួយដោយឡែកនោះទេ* ប៉ុន្តែ វាក៏បានបង្ហាញថា អំពើនេះមិនត្រូវបានមើលឃើញថាមានស្ថានទម្ងន់គ្រប់គ្រាន់ដល់កម្រិតមួយថាវាជា "អំពើអមនុស្សធម៌មួយផ្សេងទៀត" នោះទេ។ ដូចអង្គជំនុំជម្រះតុលាការកំពូលបាន

### ii. ការផ្លាស់ទីលំនៅនៅក្នុងប្រទេសភាគច្រើនពុំត្រូវបានបញ្ញត្តិនៅមុនឆ្នាំ ១៩៧៧ ទេ

10. យោងតាមធាតុផ្សំនីត្យានុកូលដ្ឋាន "ការផ្លាស់ទីលំនៅប្រជាជន" នៅក្រោមច្បាប់អន្តរជាតិ យ៉ាងហោចណាស់ ត្រូវកំណត់ជាសកម្មភាពក្នុងទម្រង់ចំនួនបីដោយឡែកពីគ្នា[20]៖ (i) ការបញ្ជូនប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដោយបង្ខំដោយប្រទេសដែលកាន់កាប់អំណាច (ii) ការបញ្ជូនដោយបង្ខំទៅកាន់រដ្ឋមួយផ្សេងទៀត ដែលត្រូវបានគេហៅជាទូទៅថាជា "ការនិរទេស" និង (iii) ការជម្លៀសដោយបង្ខំ*នៅក្នុង* ព្រំដែននៃរដ្ឋមួយ។ អនុវត្តតាមសាលាក្តី ICTY ក.ស.ព បានលើកឡើងថា ការជម្លៀសដោយបង្ខំ និងការនិរទេស គឺជាអំពើដាច់ដោយឡែកពីគ្នាអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[21]។

---

សម្រេច "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺបានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីឆ្នាំ ១៩៤៦ មកម្លេះ។ (សាលដីកាឌុច កថាខណ្ឌ ១០៨-១០៩)។ រដ្ឋាភិបាល អង្គការអន្តរជាតិ តុលាការ និងអ្នកធ្វើអត្ថាធិប្បាយដ៏វៀងវៃ ត្រូវបានគេសន្មតថាបានដឹងអំពីករណីនេះ នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីការបញ្ជូនដោយបង្ខំនៅក្នុងប្រទេសនោះ។

[20] M. Cherif Bassiouni *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (កែសម្រួល និងបោះពុម្ពលើកទីពីរ) Kluwer Law International: 1999 ("Bassiouni") ទំព័រ ៣២០ (នៅក្នុងការរៀបរាប់ប្រភេទមួយចំនួននៃការផ្លាស់ទីលំនៅប្រជាជន រួមទាំង ការនិរទេស និងការជម្លៀសប្រជាជន៖ "ច្បាប់ទំនៀមទម្លាប់នៅពេលនោះមានការវិវឌ្ឍជាវិធាន និងបទដ្ឋានផ្សេងៗគ្នាសម្រាប់ប្រភេទនីមួយៗនៅក្នុងចំណោមប្រភេទទាំងនេះ។ ចាប់តាំងពីពេលនោះមក ការវិវឌ្ឍនៃច្បាប់អន្តរជាតិពុំបានលុបចោលភាពពាក់ព័ន្ធតាមផ្លូវច្បាប់នៃការបែងចែកខុសគ្នាទាំងនេះនោះទេ"។

[21] ឯកសារលេខ D-427/1/17 "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ERN 00626531-00626650 កថាខណ្ឌ ១៩១។ នៅក្នុងកថាខណ្ឌតែមួយនេះ សហព្រះរាជអាជ្ញាក៏បានធ្វើសេចក្តីសន្និដ្ឋានផ្ទុយពីនេះថា ការនិរទេស និងការជម្លៀសដោយបង្ខំ "សំដៅលើអំពើល្មើសតែមួយ" ផ្អែកតាមលក្ខន្តិកៈទីក្រុងរ៉ូម។ លក្ខន្តិកៈទីក្រុងរ៉ូម ដែលបានចែងនូវគោលការណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ បានចាត់ទុកការនិរទេស និងការជម្លៀសដោយបង្ខំ ថាជាឧក្រិដ្ឋកម្មតែមួយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាបានផ្តល់ហេតុផលថា ការជម្លៀសដោយបង្ខំត្រូវបានកំណត់ថា ជាបទល្មើសព្រហ្មទណ្ឌនៅសាលាក្តី Nuremberg ពីព្រោះថាធម្មនុញ្ញនៃសាលាក្តី IMT បានដាក់បញ្ចូល "ការនិរទេស"។ *សូមមើលដូចគ្នា* កថាខណ្ឌ ១៩១-១៩២។ ដោយពុំចាំបាច់លើកឡើងឡើយ ហេតុផលនេះគឺមិនអាចទទួលយកបាន៖ ឋានៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដូចមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដែលត្រូវបានអនុម័តជាង ៥០ ឆ្នាំមកហើយនោះ ក្រោយធម្មនុញ្ញនៃសាលាក្តី IMT (និងជាង ២០ ឆ្នាំក្រោយហេតុការណ៍នេះ) មិនពាក់ព័ន្ធទាំងស្រុងឡើយ។ ជាការពិត ឋានៈនៃការបញ្ជូនដោយបង្ខំនៅក្រោមច្បាប់អន្តរជាតិ*បាន*

11. ខប្បញ្ញត្តិស្តីពីគោលការណ៍អនីត្យានុកូលភាពនៅក្នុងលិខិតុបករណ៍អន្តរជាតិនៅមុនឆ្នាំ ១៩៧៧ រួមទាំងលិខិតុបករណ៍ទាំងឡាយ ដែលសហចៅក្រមស៊ើបអង្កេតយកមកធ្វើជាមូលដ្ឋាននៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនផងដែរនោះ បានផ្តោតយ៉ាងខ្លាំងទៅលើទម្រង់ពីរដំបូង ដោយជាក់ស្តែងមិនមានការលើកឡើងនៃបន្លាស់ទីប្រជាជនធ្វើឡើងដោយរដ្ឋនៅក្នុងព្រំដែនរបស់ខ្លួន។ ធម្មនុញ្ញនៃសាលាក្តី IMT សាលាក្តី IMTFE និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ សុទ្ធតែបានកំណត់ "ការនិរទេស" ថាជាឧក្រិដ្ឋកម្មសង្គ្រាម និង/ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយពុំចែងយោងទៅ "ការជម្លៀសដោយបង្ខំ" ឡើយ[22]។ សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពឆ្នាំ ១៩៥៤ បានបញ្ញត្តិដូចគ្នា ពោលគឺ ចែងផ្ទុយគួរឱ្យកត់សម្គាល់ពីសេចក្តីព្រាងក្រមចុះឆ្នាំ ១៩៩៦ និងលក្ខន្តិកៈទីក្រុងរ៉ូមចុះឆ្នាំ ១៩៩៨ ដោយសេចក្តីព្រាងក្រម និងលក្ខន្តិកៈនេះ បានកំណត់អំពើទាំងពីរជាបទល្មើសព្រហ្មទណ្ឌយ៉ាងជាក់លាក់[23]។ សញ្ញាបញ្ជាក់ផ្សេងទៀតនៃច្បាប់ទំនៀមទម្លាប់

---

ឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងខ្លាំង ជាពិសេសនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដោយបានសន្និដ្ឋាននៅក្នុងលក្ខន្តិកៈ ទីក្រុងរ៉ូមថាជាគម្រូនៃការផ្លាស់ប្តូរនោះ។ *សូមមើល*កថាខណ្ឌ XX *ដូចខាងលើ*។

[22] ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ ("សាលាក្តី IMT") មាត្រា ៦ (ដែលបានផ្តល់យុត្តាធិការលើ "**(ខ) ឧក្រិដ្ឋកម្មសង្គ្រាម៖** រួមមាន ការនិរទេសទៅធ្វើការងារជាទាសករ ឬ ដើម្បីគោលបំណងផ្សេងទៀតរបស់ប្រជាជនស៊ីវិល ឬ នៅក្នុងទឹកដីនៃប្រទេសដែលត្រូវបានកាន់កាប់ និង **(គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖** រួមមាន ការនិរទេស"។ ធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦ ("ធម្មនុញ្ញ IMTFE") មាត្រា ៥ (គ) ("ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ រួមមាន...ការនិរទេស")។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យសម្រាប់ប្រទេសអាល្លឺម៉ង់ ("ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ") មាត្រា II(1) "អំពើដូចខាងក្រោម[នីមួយៗ] ត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្ម៖ (...) (ខ) *ទឹកដី*...[និង] (គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...ការនិរទេស"។ ដីកាដំណោះស្រាយកត់សម្គាល់ឃើញថា ឃ្លោងឃ្លាជាភាសាអាល្លឺម៉ង់ដែលត្រូវបានប្រើប្រាស់នៅក្នុងធម្មនុញ្ញនៃសាលាក្តី IMT រួមទាំង ការបញ្ជូននៅក្នុងព្រំដែនផងដែរ។ (*សូមមើល* ឯកសារលេខ D-427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ERN 00604508-00605246 កថាខណ្ឌ ១៣១៤ លេខយោងជើងទំព័រ ៥១៩៨)។ ភាពពុំច្បាស់លាស់បែបនេះត្រូវបានបញ្ជាក់រួចរាល់អស់ហើយដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលកំហិតយ៉ាងជាក់លាក់ត្រឹមការជម្លៀសឆ្លងព្រំដែន និងសាលក្រម ដែលពុំរួមបញ្ចូលការពិភាក្សាអំពីការបញ្ជូននៅក្នុងប្រទេសអាល្លឺម៉ង់ឡើយ។ *សូមមើល*កថាខណ្ឌ XX *ដូចខាងលើ*។

[23] ឯកសារ អ.ស.ប A/CN.4/88 របាយការណ៍នៃគណៈកម្មការនីតិកម្មអន្តរជាតិស្តីពីការងារនៃវគ្គប្រជុំលើកទី ៦ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥៤ របាយការណ៍ផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី ៩ ឯកសារបន្ថែមលេខ ៩ (A/2693) ("សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤") មាត្រា ២(១១) ("អំពើដូចខាងក្រោមនេះគឺជាបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខ...ការនិរទេស")។ សេចក្តីព្រាងក្រមស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ 51 UN GAOR ឯកសារបន្ថែម (លេខ ១០) នៅត្រង់ ១៤ ឯកសារ អ.ស.ប A/CN.4/L.532 corr.1 corr.3 (ឆ្នាំ ១៩៩៦) ("សេចក្តីព្រាងក្រមឆ្នាំ ១៩៩៦")

អន្តរជាតិនៅចន្លោះឆ្នាំ ១៩៥០ និងឆ្នាំ ១៩៧០ ក៏បានគាំទ្រយ៉ាងស៊ីសង្វាក់គ្នាលើការបែងចែករវាងការនិរទេស និងការជម្លៀស ដោយបង្ខំផងដែរ[24]។

12. បរិបទតែមួយគត់ដែលហាមលើការផ្លាស់ទីត្រូវបានទទួលស្គាល់ គឺថិតក្នុងច្បាប់នៃការគ្រប់គ្រងក្នុងពេលមានសង្គ្រាម ការហាមឃាត់ដោយផ្អែកលើ សិទ្ធិអំណាចមានកម្រិតទៅលើពេលវេលា និងវិសាលភាពនៃសិទ្ធិអំណាចរបស់ប្រទេសដែលត្រួតត្រា។ មាត្រា ៤៩ នៃអនុសញ្ញាហ្សឺណែវលើកទីបួន ហាមឃាត់ការជម្លៀស និងការនិរទេស ដោយបង្ខំ ដែលធ្វើឡើងពីសំណាក់*ប្រទេសត្រួតត្រា* ដែលអនុវត្តការជម្លៀសប្រជាជនក្រោមការត្រួតត្រារបស់ខ្លួន។ នៅក្នុងឆ្នាំ ១៩៧៥ ពុំមានភាពប្រាកដប្រជាដែលថាការហាមឃាត់នេះអនុវត្តចំពោះទម្រង់ផ្សេងទៀតនៃការជម្លៀស ប្រជាជន សូម្បីតែការជម្លៀសទាំងឡាយដែលទាក់ទងនឹងជម្លោះប្រដាប់អាវុធអន្តរជាតិក៏ដោយ[25]។ ជាការពិត គេត្រូវតែយល់នៅក្នុងបរិបទនៃច្បាប់អន្តរជាតិនៃការត្រួតត្រា ដែល

---

មាត្រា ១៨ (ឆ) ("ការនិរទេសតាមទំនើងចិត្ត ឬ ការជម្លៀសប្រជាជនដោយបង្ខំ") លក្ខន្តិកៈនៃតុលាការ ICC មាត្រា ៧(១)(ឃ) ("...ការនិរទេស ឬ ការជម្លៀសប្រជាជនដោយបង្ខំ...")។ សូម្បីនៅក្នុងឆ្នាំ ១៩៩៤ លក្ខន្តិកៈនៃសាលាក្តីមិនអចិន្ត្រៃយ៍បានទទួលស្គាល់ការនិរទេស ប៉ុន្តែ ពុំទទួលស្គាល់ការជម្លៀសដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយឡែកនោះទេ។ *សូមមើល* លក្ខន្តិកៈនៃសាលាក្តី ICTY មាត្រា ៥(ឃ)។ លក្ខន្តិកៈនៃសាលាក្តី ICTR មាត្រា ៣(ឃ)។

[24] *សូមមើល* ពិធីសារទី ៤ នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលបានចែងធានាសិទ្ធិ និងសេរីភាពមួយចំនួនក្រៅពីសិទ្ធិ និងសេរីភាពដែលត្រូវបានចែងបញ្ចូលនៅក្នុងអនុសញ្ញា និងពិធីសារទី ១ រួចហើយ CET No.: 046 ចូលជាធរមាននៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ១៩៦៨ មាត្រា ៣ ("មិនមានជនណាមួយត្រូវបានបណ្តេញចេញតាមរយៈវិធានការរួម ឬជាក្រុម *ពីទឹកដីនៃរដ្ឋដែលខ្លួនមានសញ្ជាតិឡើយ*")។ ដូចគ្នានេះដែរ សេចក្តីប្រកាសចេញដោយកងកម្លាំងសម្ព័ន្ធមិត្តនៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ ដែលបានថ្កោលទោសការអនុវត្តរបស់ណាហ្ស៊ីបានចែងជាក់លាក់អំពីការបញ្ជូនប្រជាជនឆ្លងព្រំដែន ដូចជា "ការនិរទេសជនជាតិជ្វីហ្វយកទៅសម្លាប់ចោលនៅក្នុងប្រទេសប៉ូឡូញ និងជនជាតិន័រវេ និងបារាំងយកទៅសម្លាប់ចោលនៅក្នុងប្រទេសអាល្លឺម៉ង់"។ *សូមមើល* Bassiouni ទំព័រ ៣១៧។ របាយការណ៍ឆ្នាំ ១៩១៩ នៃគណៈកម្មការទទួលខុសត្រូវលើចារី នៃសង្គ្រាម និងការដាក់ទោស ក៏បានកំណត់ "ការនិរទេស" ជាបទល្មើសព្រហ្មទណ្ឌផងដែរ។ *សូមមើល* Bassiouni ទំព័រ ៣១២-៣១៣។

[25] វិធានរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិស្តីពីច្បាប់ទំនៀមទម្លាប់, វិធាន ១២៩៖ ការផ្លាស់ទីលំនៅចែងថា៖ "(ក) ភាគីនៃជម្លោះប្រដាប់អាវុធអន្តរជាតិពុំអាចនិរទេស ឬជម្លៀសដោយបង្ខំនូវប្រជាជនស៊ីវិលនៃ *ដែនដីមួយដែលត្រូវបានត្រួតត្រា* ...(ខ) ភាគីនៃជម្លោះប្រដាប់អាវុធពុំមែនអន្តរជាតិពុំអាចបញ្ជាឱ្យមានការផ្លាស់ទីលំនៅនៃប្រជាជនស៊ីវិលឡើយ"។ បើទោះបីជាបម្រាមនៅក្នុងចំណុច (ក) ផ្អែកលើធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ និងអនុសញ្ញាសញ្ញាហ្សឺណែវទី៤ ក៏ដោយ ក៏បម្រាមនៅក្នុងចំណុច (ខ) "មានចែងក្នុង *ពិធីសារបន្ថែម II*" ដូចឯកសារយោងខាងលើ។ ការពិនិត្យមើលត្រួសៗអំពីរចនាសម្ព័ន្ធនៃអនុសញ្ញាហ្សឺណែវទី ៤ បញ្ជាក់អះអាងអំពីចំណុចនេះ។ បម្រាមស្តីពីការជម្លៀសដោយបង្ខំ ពុំត្រូវបានដាក់បញ្ចូលក្នុងផ្នែក II ("ការ

ហាមឃាត់អ្នកត្រួតត្រា មិនឲ្យអនុវត្តបុព្វសិទ្ធិភាគច្រើនរបស់រដ្ឋនោះ[26]។ ប្រភពឯកសារផ្សេងៗជាច្រើនពីសម័យកាលមុនឆ្នាំ ១៩៧៥ ហាមឃាត់ ដោយផ្ទាល់ ឬដោយប្រយោល នូវការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដែនដីដែលត្រូវបានកាន់កាប់ ដែលតាមរយៈនេះ បានបង្ហាញអំពីអត្ថិភាពជាយូរអង្វែងរបស់ខ្លួន ក្នុងលក្ខណៈជាប្រភេទបទល្មើសដោយឡែកមួយក្រោមច្បាប់នេះ[27]។

13. អ្វីដែលមិនធ្វើឲ្យមានការភ្ញាក់ផ្អើលនោះគឺ រដ្ឋអាជ្ញាទាំងនៅក្នុងសាលាក្តី IMT ទាំងនៅក្នុងសាលាក្តី NMT បានចាប់អារម្មណ៍ជាទូទៅលើការនិរទេសឆ្លងព្រំដែន*តាមផ្លូវច្បាប់*។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សាលាក្តី IMT បានកំហិតយ៉ាងជាក់លាក់លើការជម្លៀស "*ពី* ប្រទេសដែល

---

ការពារទូទៅចំពោះប្រជាជនពីផលវិបាកនានានៃសង្គ្រាម"), ផ្នែក III, ជំពូក I ("បញ្ញត្តិរួមស្តីពីដែនដីនៃភាគីជម្លោះ និងដែនដីដែលត្រូវបានត្រួតត្រា") ឬចំណុចសំខាន់គឺ ផ្នែក III , ជំពូកII ('ជនបរទេសនៅក្នុងដែនដីរបស់ភាគីមួយនៃជម្លោះ') ឡើយ ប៉ុន្តែបែរជាត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែក III ជំពូក III ("ដែនដីដែលត្រូវបានត្រួតត្រា")។ បញ្ញត្តិផ្សេងៗនៅក្នុងជំពូកដដែលនេះ ណែនាំមិនឲ្យកងកម្លាំងដែលត្រួតត្រា "ផ្លាស់ប្តូរឋានៈចៅក្រមដែលជាមន្ត្រីសាធារណៈនៅក្នុងដែនដីដែលត្រូវបានត្រួតត្រាឡើយ" (មាត្រា ៥៤) ហើយ "ច្បាប់ព្រហ្មទណ្ឌនៃដែនដីដែលត្រូវបានត្រួតត្រាត្រូវស្ថិតនៅជាធរមាន" (មាត្រា ៦៤)-ដែលជាបញ្ញត្តិដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដែនដី ដែលការរំលោភបញ្ញត្តិទាំងនោះពិតជានឹងពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។

[26] *សូមមើល* អនុសញ្ញា (IV) ពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមលើដី និងឧបសម្ព័ន្ធរបស់អនុសញ្ញានេះ៖ បទបញ្ញត្តិទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមលើដី, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧ ("អនុសញ្ញាហ្សឺណែវទីបួន"), មាត្រា ៤៣ ("ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អំណាចគ្រប់គ្រងស្របច្បាប់ ដែលតាមការពិតបានធ្លាក់ទៅក្នុងដៃរបស់អ្នកត្រួតត្រា អ្នកត្រួតត្រាត្រូវចាត់វិធានការទាំងអស់ដែលខ្លួនមានដើម្បីស្តារ និងធានាឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននូវសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព *ដោយគោរព លើកលែងតែមានការរារាំង នូវច្បាប់ជាធរមាននៅក្នុងប្រទេសដែលត្រូវបានត្រួតត្រានោះ* )។, ៥៥ ("រដ្ឋដែលត្រួតត្រា នឹងត្រូវបានចាត់ទុកជាអ្នកចាត់ចែងកិច្ចការរដ្ឋបាល និងអ្នកមានសិទ្ធិថែរក្សាអគារសាធារណៈ អចលនទ្រព្យ ព្រៃឈើ និងទុនកសិកម្មដែលជាកម្មសិទ្ធិរបស់រដ្ឋបច្ចាមិត្ត")។ David J. Scheffer, *ផលវិបាកនៅថ្ងៃខាងមុខនៃសង្គ្រាមអ៊ីរ៉ាក់៖ ហួសពីវិសាលភាពនៃច្បាប់ស្តីពីការត្រួតត្រា* 97 Am. J. Int'l L. 842, 848 (គោលដៅនៃច្បាប់ស្តីពីការត្រួតត្រាគឺដើម្បី "ជំរុញការត្រួតត្រាបណ្តោះអាសន្ន និងបង្កើតវិធានសម្រាប់ការត្រួតត្រាបណ្តោះអាសន្ននោះ")។

[27] អនុសញ្ញាទីក្រុងឡាអេទីបួន, មាត្រា ៤៦, បទបញ្ញត្តិសហរដ្ឋអាមេរិកដែលគ្រប់គ្រងការជំនុំជម្រះជនជាប់ចោទ ដែលជាឧក្រិដ្ឋជនសង្គ្រាមនៅតំបន់ប៉ាស៊ីហ្វិក I & II, 1945 (ដែលហាមឃាត់ "ការនិរទេសជនស៊ីវិលនៃ *ដែនដីដែលត្រូវបានត្រួតត្រា* ឬនៅក្នុង *ដែនដីដែលត្រូវបានត្រួតត្រា* ទៅធ្វើការងារជាទាសករ ឬសម្រាប់គោលបំណងណាមួយផ្សេង")។ *សូមមើល ផងដែរ ឧទាហរណ៍* សំណុំរឿង *Cyprus ទល់នឹង Turkey*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, ញត្តិលេខ 25781/94, 'សាលក្រម", ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០១ (ទាក់ទងការជម្លៀសប្រជាជនស៊ីពរ៍ដើមកំណើតក្រិច ដោយបង្ខំពីសំណាក់ប្រទេសទួគីនៅក្នុងប្រទេសស៊ីពរ៍ (Cyprus) ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៧៤)។

ត្រូវបានកាន់កាប់ *ទៅកាន់ប្រទេសអាល្លឺម៉ង់* និង *ប្រទេសដែលត្រូវបានកាន់កាប់ផ្សេងទៀត*"[28]។ គ្រប់ករណីនៃការផ្លាស់ទីលំនៅប្រជាជននៅក្នុងសាលក្រមរបស់សាលាក្តី IMT ដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននៅក្នុងដីកាដំណោះស្រាយ មានការពាក់ព័ន្ធទាំងការផ្លាស់ទីលំនៅឆ្លងព្រំដែន ឬនៅក្នុងទឹកដីនៃប្រទេសដែលត្រូវបានកាប់កាប់[29]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើឡើងនៅក្នុងរឿងក្តីរបស់សាលាក្តី NMT បានកំណត់ "ការនិរទេស" ជាបទល្មើសព្រហ្មទណ្ឌស្រដៀងគ្នា ហើយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសាលក្រមដែលបានចេញនៅពេលនោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានភ្ជាប់អំពើនៃការជម្លៀសជាមួយនឹងការផ្លាស់ទីឆ្លងព្រំដែន (ឬដោយប្រទេសអាល្លឺម៉ង់នៅក្នុងរដ្ឋដែលត្រូវបានកាន់កាប់)[30]។

---

[28] "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖ សាលាក្តីយោធាអន្តរជាតិ" ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញនៅក្នុងសៀវភៅស្តីពី *ការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ* Vol. I ទំព័រ ២៧-៩២("ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសាលាក្តី IMF") បទចោទទី III (ខ)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះបានបន្តផ្តល់ជាឧទាហរណ៍នៃការនិរទេសនេះ។ បុគ្គលនីមួយៗបានចូលរួមនៅក្នុងការផ្លាស់ទីឆ្លងព្រំដែនពីប្រទេសបារាំង លុចហ្សំបួរ ដាណាម៉ាក ហូឡង់ដ៍ បែលហ្ស៊ិក សហភាពសូវៀត឵ ឆេកូ និងយូហ្គោស្លាវី ទៅកាន់ទីក្រុង Buchenwald (ប្រទេសអាល្លឺម៉ង់) Dachau (ប្រទេសអាល្លឺម៉ង់) និងជារួមទៅកាន់ "ទឹកដីក្នុងប្រទេសអាល្លឺម៉ង់"។ កត់សម្គាល់ឃើញផងដែរថា នៅក្នុងបទចោទ ៤(ខ) ដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ "ឃាតកម្ម ការសម្លាប់សរង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត" កថាខណ្ឌ ១ ដែលរៀបរាប់អំពីរយៈពេលមុនចាប់ផ្តើមសង្គ្រាមពាក់ព័ន្ធនឹង "ប្រជាជននៅក្នុងប្រទេសអាល្លឺម៉ង់" បានសន្និដ្ឋានជាមួយនឹងការចោទប្រកាន់ថា ជនជាប់ចោទ "បានដាក់ប្រជាជនទាំងនេះឱ្យទទួលរងការធ្វើទុក្ខបុកម្នេញ ការបន្ទាបបន្ថោក ការដកហូតសិទ្ធិ ការដាក់ឱ្យទៅជាទាសករ ទារុណកម្ម និងឃាតកម្ម" ដោយលុបចោលការនិរទេស ហើយមានតែការនិរទេស ពីក្នុងបញ្ជីបទចោទដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះ។ បន្ទាប់មក កថាខណ្ឌ ២ លើកឡើងថា "អំពើ និងគោលនយោបាយទាំងនេះត្រូវបានបន្ត និងពង្រីកអនុវត្តរហូតដល់ទឹកដីដែលត្រូវបានកាន់កាប់ក្រោយថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៩៣៩ និងរហូតដល់ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៤៥"។

[29] សាលក្រមសាលាក្តី IMF ដែលត្រូវបានបោះពុម្ពផ្សាយឡើងវិញនៅក្នុងសៀវភៅស្តីពី *ការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ* Vol. I ទំព័រ ១៧១-៣៦៧ ("សាលាក្រមសាលាក្តី IMF") ត្រង់ទំព័រ ២២៧ ("ប្រជាជនទាំងអស់ត្រូវបាននិរទេសទៅប្រទេសអាល្លឺម៉ង់") ទំព័រ ២៣៨ (ការប្រជាជន Crimea) ទំព័រ ២៧១ ("ការនិរទេសប្រជាជនជិហ្វពីទឹកដីដែលត្រូវបានកាន់កាប់") ទំព័រ ៣០០ (ការបញ្ជូនពី Czechoslovakia ទៅកាន់ Auschwitz នៅក្នុងប្រទេសប៉ូឡូញ) ទំព័រ ៣១៩ (ការនិរទេសប្រជាជនជិហ្វនៅក្នុងទីក្រុងវីយែនទៅកាន់តំបន់រដ្ឋបាលរួម (General Government))។

[30] រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Josef Altstoeter និងជនផ្សេងទៀត* សំណុំរឿង ៣ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ២០ នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. III ទំព័រ ២៣ (ដែលសំដៅលើ "ការនិរទេស")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Ulrich Greifelt និងជនផ្សេងទៀត* សំណុំរឿង ៨ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ១៦, ២៤ នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg

Vol. IV ទំព័រ ៦១៤, ៦១៧-៦១៨ (កថាខណ្ឌ ១៦៖ ជនរងគ្រោះ "ត្រូវបានជម្លៀសដោយបង្ខំចេញពីផ្ទះរបស់ខ្លួន និងត្រូវបានបញ្ជូនទៅទឹកដីដែលត្រូវបានកាន់កាប់ផ្សេងទៀត ឬ ទៅប្រទេសអាល្លឺម៉ង់") (កថាខណ្ឌ ២៤៖ សំដៅលើ "ការនិរទេស")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Wilhelm List និងជនផ្សេងទៀត* សំណុំរឿង ៧ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ១៥ (ច) និង(ឆ) នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តី យោធា Nuremberg Vol. XI ទំព័រ ៧៧៦ (ការនិរទេសពីប្រទេសក្រូអាដទៅកាន់ប្រទេសអាល្លឺម៉ង់)។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Friedrich Flick និងជនផ្សេងទៀត* សំណុំរឿង ៥ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ១, ២ លេខយោងជើងទំព័រ ២ នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. VI ទំព័រ ១៣-១៤ (កថាខណ្ឌ ១៖ "ការជម្លៀសប្រជាជនស៊ីវិលដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងបណ្តាប្រទេស និងទឹកដីដែលស្ថិតនៅក្រោមការកាន់កាប់របស់គូសត្រូវសង្គ្រាម ឬ ប្រជាជនស៊ីវិលដ៏ច្រើនសន្ធឹកសន្ធាប់ដែលគ្រប់គ្រងដោយប្រទេសអាល្លឺម៉ង់ទៅធ្វើការងារជាទាសករ") (កថាខណ្ឌ ២៖ កម្មករប្រាំលាននាក់ "ត្រូវបាននិរទេសទៅប្រទេសអាល្លឺម៉ង់) (កថាខណ្ឌ ៣ លេខយោង ២៖ "ការនិរទេសជនជាតិសូវៀត និងឈ្លើយសឹកសង្គ្រាមទៅធ្វើការងារនៅក្នុងប្រទេសអាល្លឺម៉ង់)។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Wilhelm Von Leeb និងជនផ្សេងទៀត* សំណុំរឿង ១២ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ៦៤, ៦៥, ៦៧(ក) ៦៧(ខ) នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. X ទំព័រ ៣៧-៣៩ (កថាខណ្ឌ ៦៤៖ "យ៉ាងហោចណាស់មានកម្មករចំនួន ៥.០០០.០០០ នាក់ "ត្រូវបាននិរទេសទៅប្រទេសអាល្លឺម៉ង់"។ "បញ្ជូនដោយមានការឃោមកាមទៅប្រទេសអាល្លឺម៉ង់"។ អ្នកស្រុកនៅក្នុងប្រទេសដែលត្រូវបានកាន់កាប់ត្រូវបានកេណ្ឌ និងបង្ខំឲ្យធ្វើការងារនៅក្នុងប្រទេសរបស់ខ្លួន") (កថាខណ្ឌ ៦៥៖ ការបង្កើតគណៈកម្មការជ្រើសរើសក្នុងគោលបំណងនិរទេសទាសករពីទឹកដីដែលត្រូវបានកាន់កាប់ទៅប្រទេសអាល្លឺម៉ង់។ ត្រូវបាននិរទេសទៅប្រទេសអាល្លឺម៉ង់ ដើម្បីធ្វើការងារជាទាសករ) (កថាខណ្ឌ ៦៧(ក)៖ ជនជាតិបារាំងត្រូវបាននិរទេសទៅប្រទេសអាល្លឺម៉ង់) (កថាខណ្ឌ ៦៧(ខ)៖ ស្រដៀងគ្នា)។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Afred Krupp និងជនផ្សេងទៀត* សំណុំរឿង ១០ "ដីកាបញ្ជូនរឿងទៅជនុំជម្រះ" កថាខណ្ឌ ៦២ នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. IX ទំព័រ ៣៤-៣៥ (រៀបរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែនប៉ែកខ្លាំងទៅ Auschwitz នៅក្នុងប្រទេសប៉ូឡូញ។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Josef Altstoetter និងជនផ្សេងទៀត* សំណុំរឿង ៣ "មតិយោបល់ និងសាលក្រម" នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. III ទំព័រ ១០៤៦ (យោងលើ "ការបញ្ជូនអ្នកស្រុកនៅក្នុងទឹកដីដែលត្រូវបាន កាន់កាប់ទៅកាន់ជំរុំប្រមូលផ្តុំនៅក្នុងប្រទេសអាល្លឺម៉ង់")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Wilhelm Von Leeb និងជនផ្សេងទៀត* សំណុំរឿង ១២ "សាលក្រម" នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. XI ទំព័រ ៥៤០ ( "ប្រជាជនគ្មានទីពឹងរាប់សែននាក់នៅក្នុងទឹកដីដែលត្រូវបានកាន់កាប់ត្រូវបានគេបញ្ជូនទៅ Reich ក្រោមកម្មវិធីជ្រើសរើសកម្មករ") ទំព័រ ៥៤១ (យោងដូចគ្នាទៅរក "ការបញ្ជូនទៅ Reich")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Wilhelm List និងជនផ្សេងទៀត* សំណុំរឿង ៧ "សាលក្រម" កថាខណ្ឌ ១៥ (ច) និង(ឆ) នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Vol. XI ទំព័រ ១២៣៤, ១២៥៥-១២៥៦ ("ការជម្លៀសឲ្យទៅធ្វើការងារជាទាសករ")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង Afred Krupp និងជនផ្សេងទៀត* សំណុំរឿង ១០ "សាលក្រម នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាNuremberg Vol. IX ទំព័រ ១៤២៩-១៤៣៥ ("ការនិរទេស")។ រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Ulrich Greifelt និងជនផ្សេងទៀត* សំណុំរឿង ៨ "មតិយោបល់ និងសាលក្រម" នៅក្នុងការជំនុំ ជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាNuremberg Vol. V ទំព័រ ១០០,

14. ទំនាក់ទំនងនោះត្រូវបានបង្ហាញឱ្យឃើញច្បាស់ជាក់ស្តែងនៅក្នុងសំណុំរឿង *Milch* នៅក្នុងអត្ថបទ មួយវគ្គដែលនៅពេលក្រោយមកទៀត ត្រូវបានអនុម័តជាការថែងដ៏ត្រឹមត្រូវក្នុងច្បាប់មួយ[31]។

> ភាគីអយ្យការបានផ្តល់ភស្តុតាងដែលមានបំណងបង្ហាញថា ភាគច្រើននៃមនុស្សដែលផ្តល់ឱ្យប្រទេសអាល្លឺម៉ង់នូវមធ្យោបាយក្នុងការធ្វើសង្គ្រាមដាច់ខាត និងទាំងស្រុង ទទួលបានពីប្រជាជនដែលត្រូវបានជម្លៀសពីផ្ទះសម្បែងរបស់ពួកគាត់នៅក្នុងដែនដីដែលត្រូវបានកាន់កាប់ និងត្រូវបានបញ្ជូនចូលទៅប្រទេសអាល្លឺម៉ង់ផ្ទុយពីឆន្ទៈរបស់ពួកគាត់ និងរមែងក្រោមកាលៈទេសៈពិបាកវេទនាបំផុត។ *ការផ្លាស់ទីលំនៅរបស់ក្រុមមនុស្សពីប្រទេសមួយ ទៅកាន់ប្រទេសមួយទៀត គឺជាកង្វល់ដ៏ត្រឹមត្រូវនៃច្បាប់អន្តរជាតិ ឱ្យតែវាប៉ះពាល់ដល់សហគមន៍ប្រជាជាតិ*[32]។

15. យ៉ាងណាក៏ដោយ ការវិវត្តន៍នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនជា ទ្រង់ទ្រាយធំពីចន្លោះឆ្នាំ ១៩៤៩ ដល់ឆ្នាំ ១៩៧៧ មានតិចតួច។ ការអនុម័តពិធីសារបន្ថែម II នៃអនុសញ្ញាហ្សឺណែវ នៅខែ **មិថុនា ឆ្នាំ ១៩៧៧** គឺជា *លើកដំបូង* ដែលលិខិតុបករណ៍ដែលចងកាតព្វកិច្ចនៃច្បាប់អន្តរជាតិ បានចាត់ទុកការជម្លៀសប្រជាជនទាក់ទងជាមួយជម្លោះប្រដាប់អាវុធថាខុសច្បាប់[33]។ សេចក្តីសម្រេចលេខ ២៦៧៥ របស់មហាសន្និបាត ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៧០ ថែងថា ការជម្លៀសដោយបង្ខំក្នុងប្រទេស *ពុំ* ខុសច្បាប់ឡើយ ដោយរៀបរាប់វិធានទាំងឡាយដែលមានចែងនៅក្នុងនោះ (រួមទាំងការហាមឃាត់ការជម្លៀសដោយបង្ខំ) ថាជា "*គោលការណ៍* ជាមូលដ្ឋានសម្រាប់ការពារប្រជាជន ស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ ដោយពុំមានប៉ះពាល់ដល់ *ការបញ្ជាក់របស់ពួកគាត់នៅថ្ងៃខាងមុខ* នៅក្នុងក្របខណ្ឌនៃការវិវត្តន៍

---

១០៦, ១២៦-១២៧, ១៣១, ១៣៦, ១៣៨-១៤៣ (យោងទៅរកការនិរទេស")។ រឿងក្តី*សហរដ្ឋអាមេរិក ទល់នឹង* Ernst von Weizsaecker *និងជនផ្សេងទៀត* សំណុំរឿង ១១ "សាលក្រម" នៅក្នុងការជំនុំជម្រះនៃឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាNuremberg Vol. XIV ទំព័រ ៤៦៨-៨៦៥ (សេចក្តីយោងទៅរកការនិរទេសនៅក្នុងសាលក្រមនេះទាំងមូល)។

[31] សំណុំរឿង *សហរដ្ឋអាមេរិក ទល់នឹង Alfred Krupp et al.*, សំណុំរឿងលេខ ១០ "សាលក្រម" កថាខណ្ឌ ៦២, នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg, Volume IX, ទំព័រ ១៤៣២-៣៣។

[32] សំណុំរឿង *សហរដ្ឋអាមេរិក ទល់នឹង* Erhard Milch, សំណុំរឿងលេខ ២, 'សាលក្រម', ដែលត្រូវបានបោះពុម្ពឡើងវិញក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg, វ៉ុល II, ទំព័រ ៨៦៥។

[33] ពិធីសារបន្ថែមនៃអនុសញ្ញាហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩, និងដែលទាក់ទងនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធដែលពុំមែនជាជម្លោះអន្តរជាតិ (ពិធីសារ II), ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៧, មាត្រា ១៧។

ជាហូរហែរនៃច្បាប់អន្តរជាតិស្តីពីជម្លោះ ប្រដាប់អាវុធ"[34]។ ពិធីសារបន្ថែម II ពុំបានចងក្រងជាច្បាប់ ឬបញ្ជាក់ច្បាស់អំពីនិយាមនៃទំនៀមទម្លាប់ដែលកំពុងកើតមាន ដោយបើកចំហសម្រាប់ការចុះហត្ថលេខានៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៧ ដោយមានភាគីហត្ថលេខីចំនួនតែ ៤០ ប៉ុណ្ណោះ ដែលបន្ទាប់មកទទួលបានភាគីរដ្ឋសមាជិកចំនួន ២១ នៅក្នុងរយៈពេល ៥ ឆ្នាំដំបូងរបស់ខ្លួន។

16. ប្រភពដទៃទៀតដែលត្រូវបានលើកយកមកសំអាងនៅក្នុងដីកាដំណោះស្រាយ ដើម្បីបង្ហាញថាការជម្លៀសដោយបង្ខំ ត្រូវបានចាត់ទុកជា "អំពើអមនុស្សធម៌ផ្សេងៗ" បន្ទាប់ពីមានតុលាការយោធា Nuremberg គឺជាជំរុញដ៏ទូលំទូលាយនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងសេចក្តីប្រកាសជា សកលស្តីពីសិទ្ធិមនុស្ស ដែលគាំទ្រដល់សិទ្ធិដើម្បីទទួលបាន "សន្តិសុខផ្ទាល់ខ្លួន" "សេរីភាពនៃការដើរហើរ និងការរស់នៅ" និងការការពារពី "ការជ្រៀតជ្រែកចូល...លំនៅដ្ឋាន"[35]។ ដោយពុំចាំបាច់និយាយ ការការពារទាំងនោះពុំមែនជាការការពារដាច់ខាត ឬពុំអាចកាត់ផ្តាច់បានក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងពុំហាមឃាត់ការជម្លៀសប្រជាជនរបៀបនេះ ឬបញ្ជាក់ពីកាលៈទេសៈដែលការជម្លៀសរបៀបនេះនឹងត្រូវបានអនុញ្ញាត ឬហាមឃាត់ឡើយ[36]។ បើទោះបីជា

---

[34] ឯកសារ អ.ស.ប លេខ A/RES/2675(XXV), "គោលការណ៍មូលដ្ឋានសម្រាប់ការការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ", មហាសន្និបាត, កិច្ចប្រជុំពេញអង្គលើកទី ១៩២២ , ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧០ (សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ២៦៧៥) កថាខណ្ឌ ៧។ ខ្លឹមសារនៃពាក្យពេចន៍នេះផ្ទុយស្រឡះជាមួយពាក្យពេចន៍ដែលត្រូវបានប្រើប្រាស់នៅក្នុងកថាខណ្ឌដំបូងនៃសេចក្តីសម្រេចលេខ ៣៣១៨ ដែលដីកាដំណោះស្រាយបាន លើកមកសំអាងផងដែរ ដែល "អំពាវនាវឲ្យរដ្ឋភាគីទាំងអស់គោរពសេចក្តីប្រកាសនេះ ឲ្យបានម៉ឹងម៉ាត់"។ សេចក្តីសម្រេចលេខ ៣៣១៨ ដែលពុំមែនជាលិខិតុបករណ៍ចងកាតព្វកិច្ចដែលត្រូវបានអនុម័តិនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៤ ដែលមានរយៈពេល ៥ ខែ មុនពេលរំដោះភ្នំពេញ ទោះជាតាមមធ្យោបាយណាក៏ដោយ ពុំមែនជាបម្រាមស្តីពីការជម្លៀសដោយបង្ខំឡើយ។ ជំនួសមកវិញ សេចក្តីសម្រេចនេះបានត្រឹមតែការពារប្រឆាំងនឹង "ការបំផ្លិចបំផ្លាញលំនៅដ្ឋាន និងការជម្លៀសដោយបង្ខំ" ហើយសេចក្តីសម្រេចនេះអនុវត្តចំពោះតែស្ត្រី និងកុមារប៉ុណ្ណោះ។ *សូមមើល* ឯកសារ អ.ស.ប លេខ A/RES/3318(XXIX), 'សេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារក្នុងគ្រាអាសន្ន និងជម្លោះប្រដាប់អាវុធ" , មហាសន្និបាត, កិច្ចប្រជុំពេញអង្គលើកទី ២៣១៩, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៤, កថាខណ្ឌ ៥។

[35] ឯកសារ អ.ស.ប លេខ A/RES/217A(III), 'សេចក្តីព្រាងច្បាប់សិទ្ធិមនុស្សអន្តរជាតិ', មហាសន្និបាត, សម័យប្រជុំពេញអង្គលើកទី ១៨៣, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ('UDHR'), មាត្រា ៣, ១៣; កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦, មាត្រា ១២, ១៧។

[36] មាត្រា ៤(២) នៃកតិកាសញ្ញានេះរៀបរាប់អំពីបញ្ជីនៃសិទ្ធិដែលមិនអាចកាត់ផ្តាច់បាន ដែលពុំរាប់បញ្ចូលមាត្រា ១២ ឬ ១៧ ដែលបញ្ញត្តិទាំង ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនេះ ទំនងបំផុតត្រូវបានយល់ថាពុំស្របជា

យ៉ាងណា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលមានរដ្ឋភាគីចំនួន ៤១ នៅដំណាច់ឆ្នាំ ១៩៧៧ នៅពេលនោះ មិនបានចងកាតព្វកិច្ចកម្ពុជា ក្នុងលក្ខណៈជាបញ្ញត្តមួយនៃច្បាប់អនុសញ្ញា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[37]។

17. ហេតុដូច្នេះ បទបញ្ញត្តិអន្តរជាតិនៃការជម្លៀសក្នុងប្រទេស មុនពេលការជម្លៀសប្រជាជនដំណាក់កាលទី II បានបញ្ចប់ក្នុងឆ្នាំ ១៩៧៧ ស្ថិតក្នុងដំណាក់កាលដំបូងបំផុតរបស់ខ្លួន និងផ្ទុយខុសស្រឡះពីវិធានដែលអនុវត្តចំពោះការជម្លៀសឆ្លងដែន ឬនៅក្នុងដែនដីដែលត្រូវបានត្រួតត្រា។ បើទោះបីជាការជម្លៀសឆ្លងដែន និង ការជម្លៀសនៅក្នុងដែនដីដែលត្រូវបានត្រួតត្រា ត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មអន្តរជាតិចាប់តាំងពី *យ៉ាងហោចណាស់* សង្គ្រាមលោកលើកទី ២ ក៏ដោយ ក៏ការជម្លៀសក្នុងប្រទេស ត្រូវបានហាមឃាត់មួយផ្នែកដោយប្រយោល និងនៅក្នុងទម្រង់ដែលពុំចងកាតព្វកិច្ច ដោយសេចក្តីសម្រេចរបស់មហាសន្និបាត ៥ ខែ មុនពេលរំដោះភ្នំពេញ[38]។

---

មួយការជម្លៀសដោយបង្ខំ។ ប្រការសំខាន់ នៅក្នុងយោបល់ទូទៅលេខ ២៩ ដែលបានចេញក្នុងឆ្នាំ ២០០១ គណៈកម្មាធិការសិទ្ធិមនុស្សនេះបានសន្និដ្ឋានថាមាត្រា១២បាន*ប្រែក្លាយជា* មាត្រា ដែលពុំអាចផ្តាច់ចេញបានចាប់តាំងពីពេលនោះមក ដោយហេតុថាការជម្លៀសដោយបង្ខំ *នាពេលបច្ចុប្បន្ន* ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម។ *សូមមើល* ឯកសារ អ.ស.ប លេខ CCPR/C/21/Rev.1/Add.11, យោបល់ទូទៅលេខ ២៩, ស្ថានភាពអាសន្ន (មាត្រា ៤) (2001), កថាខណ្ឌ១៣(ឃ)។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស ប្រការនេះនាំឲ្យការជម្លៀសដោយបង្ខំ*ពុំមែនជាអំពើឧក្រិដ្ឋ* នៅពេលដែលកតិកាសញ្ញានេះត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៦៦។ *សូមមើលផងដែរ*, Bassiouni, ទំព័រ ៣២៥ (ដែលរៀបរាប់អំពីគម្លាតរវាងការទទួលស្គាល់សិទ្ធិនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស និងការកំណត់ជាបទឧក្រិដ្ឋនៃអំពើមួយដែលរំលោភលិខិតុបករណ៍នោះ ដោយរួមបញ្ចូលទាំងការការពារសិទ្ធិដែលពុំមានចរិតដាច់ខាត)។ បញ្ញត្តិនៃសិទ្ធិមនុស្សថ្នាក់តំបន់ដែលមានកាលពីពេលនោះ ដែលការពារផលប្រយោជន៍ស្រដៀងគ្នា ក៏អាចកាត់ផ្តាច់បាន និងស្ថិតក្រោមការដាក់កំហិត ដោយសារមូលហេតុសុខភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងចំណោមមូលហេតុផ្សេងៗ។ *សូមមើល* អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស , មាត្រា ៨(២), មាត្រា ១៥(១),(២); អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស, ដែលបានចូលជាធរមាននៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨, មាត្រា ២២(៣), ២៧(១),(២)។ មកទល់នឹងឆ្នាំ ១៩៧៧ ពុំមានច្បាប់យុត្តិសាស្ត្រពីគណៈកម្មាធិការសិទ្ធិមនុស្សដែលបកស្រាយបញ្ញត្តិទាំងនេះឡើយ។ ច្បាប់យុត្តិសាស្ត្រមួយចំនួនតូចពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលពាក់ព័ន្ធនឹងមាត្រា ៨ ពុំអាចអនុវត្តបានចំពោះករណីនេះឡើយ។

37 ជាការពិត កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពុំបានចូលជាធរមានក្នុងប្រភេទជាបញ្ញត្តមួយនៃច្បាប់អនុសញ្ញាឡើយ រហូតដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦។

38 *សូមមើល* ជើងទំព័រ XX, ខាងលើ។

### iii. ទម្លាប់អនុវត្តរបស់រដ្ឋ និង *ទស្សនៈច្បាប់ (Opinio Juris)* បានទទួលស្គាល់សិទ្ធិអំណាចនៃអធិបតេយ្យភាពទូលំទូលាយ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនផ្ទៃក្នុងរវាងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧

18. ប្រតិកម្មស្ងៀមស្ងាត់នៃលិខិតុបករណ៍អន្តរជាតិចំពោះការផ្លាស់ទីលំនៅក្នុងប្រទេស ត្រូវបានយកធ្វើជាគំរូនៅក្នុងទម្លាប់អនុវត្តន៍របស់រដ្ឋជាទូទៅ ដែលអនុលោមតាមទម្លាប់អនុវត្តន៍នេះ គម្រោងនានាដែលបានបណ្តាលឱ្យមានការផ្លាស់ទីលំនៅដោយបង្ខំក្នុងប្រទេសជាទ្រង់ទ្រាយធំ ត្រូវបានចាត់ទុកថាអាចទទួលយកបានយ៉ាង ទូលំទូលាយ។ គម្រោងទាំងនោះស្ទើរតែពុំត្រូវបានចោទប្រកាន់ថាខុសច្បាប់ឡើយ និងត្រូវបានផ្តល់ថវិកា និងការគាំទ្រជាទៀងទាត់ដោយអង្គការអន្តរជាតិមួយចំនួនទៀតផង រួមទាំងធនាគារពិភពលោក និងអង្គការសហប្រជាជាតិ[39]។

19. របាយការណ៍មួយរបស់ អ.ស.ប រៀបរាប់អំពីគោលដៅនៃកម្មវិធីដោះស្រាយដីធ្លី ក្រោមចំណុចធំៗបួន៖

(i) ពាក់ព័ន្ធនឹងការចែកដីធ្លីឡើងវិញ កម្មវិធីនេះមានគោលដៅសម្រាលសម្ពាធរបស់ប្រជាជននៅក្នុងតំបន់ដែលមានមនុស្សរស់នៅកកកុញ (ii) ពាក់ព័ន្ធនឹងផ្នែកសេដ្ឋកិច្ច កម្មវិធីនេះមានគោលដៅបង្កើនប្រាក់ ចំណូលជាតិ ឬប្រាក់ចំណូលរបស់មនុស្សម្នាក់ៗ ឬបង្កើនការងារកសិកម្ម ឬផលិតកម្ម។ (iii) ពាក់ព័ន្ធនឹង សង្គម កម្មវិធីនេះមានគោលដៅធ្វើឱ្យរដ្ឋាភិបាលអាចផ្គត់ផ្គង់បានកាន់តែទាន់ពេលវេលានូវសេវានានាសម្រាប់ប្រជាជនដែលបានតាំងទីលំនៅតាមទីប្រជុំជនតូចៗ (iv) ពាក់ព័ន្ធនឹងនយោបាយ កម្មវិធីនេះមាន គោលដៅបញ្ចៀសការរឹបអូសដីស្រែចម្ការ ដែលបណ្តាលមកពីកំណែទម្រង់ដីធ្លី ឬដើម្បីបម្រើសេវា ប្រជាជនមួយផ្នែកខ្លះ[40]។

---

[39] Bassiouni រៀបរាប់អំពីការពិភាក្សាមួយក្នុងអំឡុងការជំនុំជម្រះនៅឯតុលាការយោធាអន្តរជាតិ ដែលមេធាវីការពារក្តីបានប៉ុនប៉ងរៀបរាប់អំពីការនិរទេសប្រជាជនអាឡឺម៉ង់ពី Silesia និង Sudetenland ភ្លាមៗក្រោយសង្គ្រាម ប៉ុន្តែត្រូវបានរំខានដោយតុលាការនេះដោយមូលហេតុថាអំពើទាំងនោះ "ពុំពាក់ព័ន្ធនឹងសំណុំរឿងនាពេលបច្ចុប្បន្ន"។ Bassiouni សង្កេតឃើញថា៖ 'ក្រៅពីភាពលម្អៀងដែលត្រូវបានអនុវត្ត *ទង្វើករណីនេះមានភាពពាក់ព័ន្ធផ្នែកគតិយុត្តដើម្បីបង្ហាញថាការត្រឹមតែជម្លៀសប្រជាជន ពុំផ្ទុយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយចាប់តាំងពីការជម្លៀសនេះត្រូវបានអនុវត្ត សូមមើល* Bassiouni, ទំព័រ ៣១៩។

[40] G.W. Jones and H.V. Richetr (eds), *កម្មវិធីតាំងទីលំនៅឡើងវិញរបស់ប្រជាជននៅអាស៊ីអាគ្នេយ៍* (Canberra: សាកលវិទ្យាល័យជាតិអូស្ត្រាលី, ឆ្នាំ ១៩៨២) ('Jones និង Richter'), ទំព័រ ៣-៤។

គោលដៅទី ២ គឺជាគោលដៅដ៏មានសារៈសំខាន់ជាពិសេស នៅអាស៊ីអាគ្នេយ៍ ដែលគិតត្រឹមឆ្នាំ ១៩៨២ 'រដ្ឋាភិបាល...ភាគច្រើន [បាន] បង្កើតកម្មវិធីដើម្បីធ្វើឲ្យមនុស្សតាំងទីលំនៅឡើងវិញនៅក្នុងតំបន់នានាដែលមាន សក្ដានុពលលើការអភិវឌ្ឍន៍ [ខាងកសិកម្ម]'[41]។ ជារឿយៗ និងជាពិសេសនៅក្នុងករណីនៃរដ្ឋឯករាជ្យថ្មី សិល្បៈនយោបាយនៃគោលដៅទាំងនេះតែងតែផ្សារភ្ជាប់ជាមួយនឹងការកសាងជាតិ និងសារៈសំខាន់នៃការលះបង់ដើម្បី ផលប្រយោជន៍របស់រដ្ឋ[42]។

> ជាទូទៅ នៅមុនទសវត្សរ៍ឆ្នាំ ១៩៩០ កម្មវិធីនានាដែលត្រូវបានអនុវត្តសម្រាប់គោលបំណងទាំងនេះ ពុំត្រូវបានចាត់ទុកជាកម្មវិធីដែល *ពុំល្អ* ទេ កុំថាឡើយជាកម្មវិធី *ពុំស្របច្បាប់*។ ធនាគារពិភពលោក ដែលអាចជាអ្នកផ្ដល់កម្ចីលើកិច្ចការអភិវឌ្ឍន៍ធំជាងគេរបស់ពិភពលោកក៏ថាបាន ដែលមានរដ្ឋសមាជិកចំនួន ១៨៧ ពុំមានសូម្បីតែ *គោលនយោបាយ* ឆ្ពោះទៅរកការតាំងទីលំនៅឡើងវិញក្នុងប្រទេស ជាសម្រាប់ គម្រោងដែលស្ថិតក្រោមការផ្ដត់ផ្គង់ហិរញ្ញវត្ថុពីធនាគារមុនខែកុម្ភៈ ឆ្នាំ ១៩៨០[43]។

20. និន្នាការទូទៅទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបញ្ជីដែលស្ទើរតែគ្មានទីបញ្ចប់នៃការការផ្លាស់ទីលំនៅ ក្នុងប្រទេសដែលត្រូវបានដាក់ទណ្ឌកម្ម។ តាមការពិត នៅទូទាំងប្រទេស ឥណ្ឌា ចិន និងអាហ្វ្រិក ប្រជាជនចំនួន *រាប់លាននាក់* ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៩០ ដោយសារតែសំណង់ឧស្សាហកម្ម រ៉ែ និងទំនប់ សង្គ្រាម គ្រោះអត់ឃ្លាន បញ្ហាបរិស្ថាន និងនគរូបនីយកម្ម[44]។ នៅអាហ្វ្រិកតែនៅចន្លោះពីឆ្នាំ ១៩៨១ ដល់ ១៩៩៤ ធនាគារពិភពលោក

---

[41] Jones និង Richter, ទំព័រ ៣។

[42] R.H.B.B.S. Samiti, H. Mander, និង V. Nagaraj, 'ទំនប់, ការផ្លាស់ទីលំនៅ, គោលនយោបាយ និងច្បាប់នៅក្នុងប្រទេសឥណ្ឌា', ឯកសាររួមចំណែកដល់គណៈកម្មការពិភពលោកស្ដីពីទំនប់, ទំព័រ vii (ដែលរៀបរាប់អំពីការរំឭកដាស់តឿនរបស់នាយករដ្ឋមន្ត្រី Nehru ទៅកាន់អ្នកផ្លាស់ទីលំនៅថា 'ប្រសិនបើអ្នកត្រូវរងគ្រោះ អ្នកគួរធ្វើដូច្នេះដើម្បីផលប្រយោជន៍ប្រទេសជាតិ'); C. De Wet, 'បទពិសោធន៍ជាមួយទំនប់ និងការតាំងទីលំនៅឡើងវិញនៅអាហ្វ្រិក', ឯកសាររួមចំណែកដល់គណៈកម្មការពិភពលោកស្ដីពីទំនប់, ទំព័រ ៦-៧ (ទំនប់រមែងត្រូវបានចាត់ទុកជា 'មូលដ្ឋាននៃគម្រោងថ្នាក់ជាតិដែលរមែងមានលក្ខណៈជាតិនិយម')។

[43] M.M.Cernea, 'ការតាំងទីលំនៅដោយពុំមានការស្ម័គ្រចិត្តនៅក្នុងគម្រោងអភិវឌ្ឍន៍៖ គោលការណ៍ណែនាំស្ដីពីគោលនយោបាយនៅក្នុងគម្រោងដែលផ្ដត់ផ្គង់ហិរញ្ញវត្ថុដោយធនាគារពិភពលោក', ឯកសារបច្ចេកទេសរបស់ធនាគារពិភពលោក លេខ ៨០ ឆ្នាំ ១៩៨៨ ទំព័រ ១-២។

[44] N. S. Negi និង S. Ganguly, 'គម្រោងអភិវឌ្ឍន៍ ទល់នឹង ប្រជាជនដែលត្រូវបានជម្លៀសផ្ទៃក្នុងនៅឥណ្ឌា៖ ការវាយតម្លៃដោយផ្អែកលើទ្រឹស្ដី', ឯកសារការងារ, សន្និសីទស្រាវជ្រាវស្ដីពី 'បម្រែបម្រួលបរិស្ថាន និងទេសន្តប្រវេសន៍៖ ពីភាពងាយ

បានគាំទ្រគម្រោងអភិវឌ្ឍន៍ក្នុងទ្រង់ទ្រាយធំ ដែលបានបណ្តាលឲ្យមានការផ្លាស់ទីលំនៅក្នុងប្រទេសដោយពុំមានការស្ម័គ្រចិត្តនៅក្នុងប្រទេសចំនួន ៣៨[45]។

21. ការផ្លាស់ទីលំនៅណាមួយក្នុងចំណោមការផ្លាស់ទីលំនៅទាំងនេះនឹងបានតម្រូវ *ដោយស្វ័យប្រវត្ត* ឲ្យមានការទទួលខុសត្រូវឧក្រិដ្ឋកម្មអន្តរជាតិ ប្រសិនបើការជម្លៀសនេះត្រូវបានធ្វើឆ្លងកាត់ *តាមព្រឹត្តិន័យ (de jure)* ឬ *តាមជាក់ស្តែង (de facto)* ព្រំដែន ឬបានកើតឡើងនៅក្នុងដែនដីដែលត្រូវបានកាន់កាប់។ ហេតុដូច្នេះ ជាអប្បបរមា ទម្លាប់អនុវត្តរបស់រដ្ឋបង្ហាញថា "ការផ្លាស់ទីលំនៅដោយបង្ខំ" *ដូចករណីខាងលើ* ពុំត្រូវបានហាមឃាត់នៅក្នុងរយៈកាលពាក់ព័ន្ធឡើយ។

### iv. ទស្សនៈអន្តរជាតិបានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅទូទាំងទសវត្សរ៍ឆ្នាំ ១៩៩០

22. ឥរិយាបទអនុគ្រោះចំពោះការផ្លាស់ទីលំនៅក្នុងប្រទេសដោយបង្ខំ បានប្រែប្រួលច្រើននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ អំឡុងពេលរដ្ឋ និងអង្គការអន្តរជាតិ បានអនុវត្តសកម្មភាពយ៉ាងរួសរាន់ និងស្វាហាប់។ នៅចន្លោះឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០០ អង្គការអន្តរជាតិ រួមទាំងគណៈកម្មការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស គណៈកម្មាធិការសិទ្ធិមនុស្ស គណៈកម្មការច្បាប់អន្តរជាតិ និងអគ្គលេខាធិការ អ.ស.ប ក្នុងចំណោមស្ថាប័នដទៃទៀត បានផ្លាស់វេនគ្នាក្នុងការរិះគន់ ឬចោទប្រកាន់ដើម្បីហាមឃាត់ការផ្លាស់ទីលំនៅក្នុង ប្រទេស[46]។ សមាជិកនៃសន្និសញ្ញាពហុភាគីសំខាន់ៗ រួមទាំងពិធី

---

ទទួលរងគ្រោះ ទៅដល់ការមានសមត្ថភាព', Bad Salzuflen, អាល្លឺម៉ង់, ថ្ងៃទី ៥-៩ ខែ ធ្នូ, ទំព័រ ៦ (ប្រជាជនចំនួន ២១ លាននាក់បានផ្លាស់ទីលំនៅក្នុងប្រទេសឥណ្ឌាចន្លោះពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៩០); L. Heming *et al.*, 'ការតាំងទីលំនៅនៅឯអាងស្តុកទឹកនៅក្នុងប្រទេសចិន៖ បទពិសោធន៍អតីតកាល និងមហាទំនប់ទាំង ៣', (2001) 167 *The ព្រឹត្តិប័ត្រភូមិសាស្ត្រលេខ* 195, ទំព័រ ១៩៧។

[45] Scudder, ទំព័រ ៥-៦ ត្រង់ចំណុចអនុស្សរណៈ GS, ទំព័រ ១២។

[46] សេចក្តីសម្រេចលេខ 1992/28, កិច្ចប្រជុំលើកទី ៣៥, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩២, កថាខណ្ឌ ២ និងកថាខណ្ឌ ៨ ដែលត្រូវបានដាក់បញ្ចូលក្នុងឯកសារ អ.ស.ប លេខ E/CN.4/Sub.2/1992/L.11/Add.4, 'របាយការណ៍ព្រាងនៃអនុគណៈកម្មការស្តីពីការការពារការរើសអើង និងការការពារជនជាតិភាគតិច', ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩២, ទំព័រ ១៨-១៩ (ការតែងតាំងអ្នកធ្វើរបាយការណ៍ពិសេសស្តីពីបញ្ហាសិទ្ធិមនុស្ស និងការជម្លៀសប្រជាជន ('អ្នករាយការណ៍ពិសេស') របស់គណៈកម្មការ អ.ស.ប នៃអនុគណៈកម្មការសិទ្ធិមនុស្សស្តីពីការទប់ស្កាត់ការរើសអើង និងការការពារជនជាតិភាគតិច ('អនុគណៈកម្មការ')); សេចក្តីព្រាងក្រមឆ្នាំ ១៩៩៦, មាត្រា ១៨ (ឆ) (ការហាមឃាត់ការជម្លៀសដោយបង្ខំ)។ ឯកសារ អ.ស.ប លេខ E/CN.4/1998/2 & E/CN.4/Sub.2/1997/50, 'របាយការណ៍របស់អនុគណៈកម្មការ អ.ស.ប ស្តីពីការរារាំងការរើសអើង និងការការពារជនជាតិភាគតិចនៅក្នុងសម័យប្រជុំលើកទី ៤៩ របស់ខ្លួន, ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ (ការអនុម័តិសេចក្តី

សារបន្ថែម II (ពីរដ្ឋភាគីចំនួន ០ ក្នុងឆ្នាំ ១៩៧៧ ទៅដល់ចំនួន ១៣០ ក្នុងឆ្នាំ ១៩៩៥) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ពីភាគីចំនួន ៤១ ក្នុងឆ្នាំ ១៩៧៧ ទៅដល់ ១៣០ ក្នុងឆ្នាំ ១៩៩៥) បានប្រែប្រួលយ៉ាងច្រើន។ នៅក្នុងសេចក្តីសង្ខេបជាក់លាក់មួយ សមូហកម្មរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិស្តីពីទម្លាប់អនុវត្តន៍ជាអន្តរជាតិទាក់ទងនឹងវិធាន ១២៩ ("ច្បាប់ស្តីពីការផ្លាស់ទីលំនៅ") មាន*ទាំងអស់* នូវឧទាហរណ៍នានាពីរយៈកាលក្រោយឆ្នាំ ១៩៩០ ដែលភាគច្រើនត្រូវបានជំរុញដោយសង្គ្រាមនៅក្នុងអតីតយូហ្គោស្លាវី[47]។

23. វិសាលភាព និងសារៈសំខាន់នៃសញ្ញាណទាំងនេះនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំដ៏ខ្លីនេះ បង្ហាញថា នៅទសវត្សរ៍ឆ្នាំ ១៩៩០ មានបម្រែបម្រួលដ៏ធំនៅក្នុង (អ) និត្យានុកូលភាពអន្តរជាតិនៃការជម្លៀសក្នុងប្រទេសដោយបង្ខំ។ ហេតុដូច្នេះ និយាយឲ្យខ្លី ការសំអាងលើ

---

ប្រកាសព្រាងស្តីពីការជម្លៀសប្រជាជន និងការផ្សាំអ្នកតាំងទីលំនៅលើតំបន់ថ្មីដោយអនុគណៈកម្មការនេះ)។ ឯកសារ អ.ស.ប លេខ E/CN.4/1998/53/Add.2, 'របាយការណ៍របស់តំណាងអគ្គលេខាធិការ, លោក Francis M. Deng, ដែលត្រូវបានដាក់ដោយអនុលោមតាមសេចក្តីសម្រេចលេខ ១៩៩៧/៣៩ របស់គណៈកម្មការ–សេចក្តីបន្ថែម, គោលការណ៍ទូទៅស្តីពីការផ្លាស់ទីលំនៅផ្ទៃក្នុង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ (ការចេញគោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅផ្ទៃក្នុងពីសំណាក់អ្នករាយការណ៍ពិសេសរបស់អគ្គលេខាធិការ)។ លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ, មាត្រា ៧(១)(ឃ) (ការហាមឃាត់ការជម្លៀសដោយបង្ខំ)។ ឯកសារ អ.ស.ប លេខ CCPR/C/21/Rev.1/Add.9, 'មតិយោបល់ទូទៅដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៤០, កថាខណ្ឌ ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – សេចក្តីបន្ថែម, មតិយោបល់ទូទៅលេខ 27 (67) – សេរីភាពនៃការដើរហើរ, មាត្រា ១២', ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩, កថាខណ្ឌ ៧ (ការហាមឃាត់ 'ការជម្លៀសផ្ទៃក្នុងរាល់គ្រប់ទម្រង់ទាំងអស់')។ សាលក្រមនៃការជំនុំជម្រះ Kupreskic, កថាខណ្ឌ ៥៦៦ (ដែលចាត់ទុកការជម្លៀសដោយបង្ខំ ជាអំពើអមនុស្សធម៌មួយផ្សេងទៀត)។

[47] *សូមមើល* 'ទម្លាប់អនុវត្តន៍ទាក់ទងនឹងវិធាន ១២៩។ ការផ្លាស់ទីលំនៅ' នៅលើគេហទំព័រ http://www.icrc.org/customary-ihl/eng/docs/v2_rul_rule129_sectiona។ ឧទាហរណ៍មួយចំនួនតូចមុនឆ្នាំ ១៩៩០ ពាក់ព័ន្ធទាំងស្រុងជាមួយការនិរទេស ឬការត្រួតត្រាប្រកបដោយភាពប្រទូស្តរាយ (រួមទាំងប្រភពឯកសារច្បាប់ដែលត្រូវបានពិភាក្សារួចហើយ និងឧទាហរណ៍នានានៃទម្លាប់អនុវត្តដូចជា ការត្រួតត្រារបស់អ៊ីស្រាអែល ឬការនិរទេសជនស៊ីវិលអ៊ីរ៉ង់ទៅអ៊ីរ៉ាក់ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០), ដោយបង្កើនភាពខុសគ្នារវាងទម្រង់នៃការជម្លៀសទាំងនោះ ជាមួយការជម្លៀសដោយបង្ខំផ្ទៃក្នុង។ *សូមមើលឧទាហរណ៍* Frédéric de Mulinen, 'សៀវភៅមគ្គុទេសន៍ស្តីពីច្បាប់នៃសង្គ្រាមសម្រាប់កងកម្លាំងប្រដាប់អាវុធ', គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, ហ្សឺណែវឆ្នាំ ១៩៨៧, កថាខណ្ឌ ៧៧៦(ច) ('ការនិរទេស ឬការជម្លៀសដោយខុសច្បាប់នូវប្រជាជនទាំងអស់ ឬមួយផ្នែក*នៃដែនដីដែលត្រូវបានត្រួតត្រា*)។ សន្និសីទអន្តរជាតិលើកទី ២៥ របស់កាកបាទក្រហម, ហ្សឺណែវ, ថ្ងៃទី ២៣-៣១ ខែ តុលា ឆ្នាំ ១៩៨៦, សេចក្តីសម្រេច I, បុព្វកថា ('ការផ្លាស់ទីលំនៅរបស់ប្រជាជនស៊ីវិលដោយបង្ខំពីសំណាក់ *ទ័ពត្រួតត្រា*)។ *រៀងរាល់* ឧទាហរណ៍នៃការអនុវត្តដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅផ្ទៃក្នុង គឺនៅក្រោយឆ្នាំ ១៩៩០។

ប្រភពណាមួយពីរយៈកាលនោះតរៀងមក ដើម្បីបញ្ជាក់អំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់ក្នុងឆ្នាំ ១៩៧៥ ពុំអាចឲ្យជឿជាក់បានឡើយ។

## V. ធាតុផ្សំនៃការជម្លៀសដោយបង្ខំដែលជាអំពើអមនុស្សធម៌មួយផ្សេងទៀត

24. ដូចបានកត់សម្គាល់ខាងលើ ពាក្យពេចន៍នៅក្នុងនិយមន័យនៃការជម្លៀសដោយបង្ខំដែលជាអំពើអមនុស្សធម៌មួយផ្សេងទៀតដូចបានពិពណ៌នានៅក្នុងដីកាដំណោះស្រាយ ត្រូវបានដកចេញមកពីធាតុផ្សំនៃឧក្រិដ្ឋកម្មនៅតុលាការ ICC យ៉ាងច្បាស់ ពីព្រោះថានិយមន័យនេះបានចាត់ទុកការជម្លៀសប្រជាជនដោយបង្ខំជាបទល្មើសព្រហ្មទណ្ឌមួយដោយត្រូវគោរពតាម "មូលហេតុដែលត្រូវបានអនុញ្ញាតតាមច្បាប់អន្តរជាតិ" មួយចំនួនដែលពុំបានចែងច្បាស់លាស់។ ខ្លឹមសារនៃមូលហេតុដែលត្រូវបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិដូចដែលបានពិពណ៌នាដោយសហចៅក្រមស៊ើបអង្កេតបានផ្អែកលើមាត្រា ៤៩(២) នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួន ដែលចែងធានានូវ "សន្តិសុខប្រជាជន" និង "ភាពចាំបាច់ផ្នែកយោធា។ យោងតាមហេតុផលដូចបានលើកឡើងខាងលើ គ្មានប្រភពច្បាប់ណាមួយអាចយកមកអនុវត្តដើម្បីបញ្ជាក់បំភ្លឺលើនិយមន័យនៃការជម្លៀសដោយបង្ខំថាជាអំពើអមនុស្សធម៌ផ្សេងមួយទៀតនៅក្នុងឆ្នាំ ១៩៧៥ ឡើយ។

25. ដោយកត់សម្គាល់ឃើញនូវភាពពុំស៊ីសង្វាក់គ្នានៃការអនុវត្តរបស់រដ្ឋ Bassiouni បានផ្តល់ទស្សនៈករណ៍ថា ការជម្លៀសដោយបង្ខំមិនមែនមិនស្របច្បាប់ឡើយ ប៉ុន្តែ អំពើនេះអាច*ក្លាយជា* ខុសច្បាប់ អាស្រ័យលើគោលបំណង និងទង្វើនៃការអនុវត្តនោះតែប៉ុណ្ណោះ ពោលគឺ "[វា] ពុំមែន ថាការជម្លៀសប្រជាជនស៊ីវិលនៅក្នុងទឹកដីនៃប្រទេសមួយគឺជាការរំលោភបំពាននោះទេ ប៉ុន្តែការជម្លៀសក្នុងគោលបំណងដើម្បីយកទៅសម្លាប់រង្គាល ធ្វើទាសភាព ការអនុវត្តបែបទាសភាព និងការងារជាទាសករទេដែលជាអំពើរំលោភបំពាននោះ។ *ការនិរទេស និងការជម្លៀសប្រជាជនរបស់រដ្ឋ" ជាតួសត្រូវសង្គ្រាម នៅតែជាឧក្រិដ្ឋកម្មសង្គ្រាមដដែល*"[48]។

26. ក្រុមមេធាវីការពារក្តីសូមសន្និដ្ឋានថា វិធីសាស្ត្រកំណត់តាមបរិបទបែបនេះគឺជាវិធីតែមួយគត់សម្រាប់បង្ហាញឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំថាជាអំពើអមនុស្សធម៌មួយផ្សេងទៀតនៅ

---

[48] Bassiouni ទំព័រ ៣១៥។ នៅក្នុងករណីនៃការជម្លៀសដោយបង្ខំដែលស្របតាមច្បាប់ Bassiouni បានដាក់ជនជាតិជប៉ុនសញ្ជាតិអាមេរិកដែលត្រូវបានបញ្ជូនជាឈុត នៅក្នុងជំរំប្រមូលផ្តុំនៅក្រោយសង្គ្រាមលោកលើកទីពីរ បើទោះជាពុំមានការដកហូតសិទ្ធិដើរហើរក៏ដោយ។ *សូមមើលដូចខាងលើ* ទំព័រ ៣២០។

ចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ ដោយត្រូវគោរពទៅតាមគោលការណ៍នីត្យានុកូលភាព និង ប្រភពច្បាប់ទំនៀមទម្លាប់ជាធរមាននៅក្នុងពេលនោះ។ បទដ្ឋាន *ជាក់លាក់* តែមួយគត់ដែលមាននៅក្នុងច្បាប់ ចេញមកពីច្បាប់ស្តីពីការនិរទេស និងការកាប់កាប់ដោយគូសត្រូវសង្គ្រាម ដែលចំណុចទាំងពីរនេះពុំអាចយកមកអនុវត្តបានដោយត្រង់ៗតែម្តងចំពោះការជម្លៀសដោយបង្ខំនោះទេ។

27. យោងតាមហេតុផលទាំងអស់នេះហើយ ធាតុផ្សំនៃការជម្លៀសដោយបង្ខំដោយពុំស្ម័គ្រចិត្តនៅក្នុងប្រទេស ដែលជាអំពើអមនុស្សធម៌មួយផ្សេងទៀតនៅចន្លោះខែ មេសា ឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៧ គ្រាន់តែអាចត្រូវបានពិពណ៌នាដោយពាក្យពេចន៍ទូទៅបំផុត៖ (i) ជនរងគ្រោះត្រូវបានបង្ខំឲ្យចាកចេញពីទីកន្លែងមួយដែលខ្លួនរស់នៅដោយស្របច្បាប់ (ii) ក្រោមកាលៈទេសៈនានា រួមទាំង គោលបំណងនៃការបង្ខំឲ្យចាកចេញ ទង្វើនៃការអនុវត្ត និងផលប៉ះពាល់ ដែលមើលឃើញនៅពេលនោះថាមានស្ថានទម្ងន់ស្មើគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដូចមានចែងនៅក្នុងច្បាប់ (iii) ជនជាប់ចោទមានចេតនា[49] បង្ខំជនរងគ្រោះឲ្យចាកចេញពីទីកន្លែងដែលពួកគេរស់នៅដោយស្របច្បាប់ និង (iv) ជនជាប់ចោទមានចេតនាធ្វើបែបនេះនៅក្រោមកាលៈទេសៈដែលធ្វើឲ្យការជម្លៀសនេះជាបទល្មើសព្រហ្មទណ្ឌ។ ដើម្បីកំណត់ថា អំពើជាក់លាក់ណាមួយបានបំពេញទៅតាមនិយមន័យនេះឬក៏អត់នោះ វាតម្រូវឲ្យមានការវិភាគលម្អិតលើអង្គហេតុនៃកាលៈទេសៈទាំងអស់ដោយពិចារណាលើការអនុវត្តរបស់រដ្ឋបច្ចុប្បន្ននៅក្នុងអំឡុងពេលនោះ។

## គ. សហឧក្រិដ្ឋរួម

<u>i - ធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម៖ ធាតុផ្សំទូទៅ</u>

28. អនុលោមតាមកថាខណ្ឌ ១៥៤០ នៃដីកាដំណោះស្រាយ នួន ជា ត្រូវបានចោទប្រកាន់ថាបាន "ប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយនេះ" ក្នុងឋានៈរបស់ខ្លួន ជាសមាជិកសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មរួម")[50]។ សហឧក្រិដ្ឋកម្មរួមរួមមាន ការទទួលខុសត្រូវព្រហ្មទណ្ឌលើការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយតាមរយៈការចូលរួមរបស់ជនជាប់ចោទនៅក្នុង

---

[49] គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាមទារលក្ខខណ្ឌថា ជនជាប់ចោទមានចេតនាលើធាតុសត្យានុម័តនីមួយៗនៃបទល្មើស។ *សូមមើល* លក្ខន្តិកៈរបស់តុលាការ ICC មាត្រា ៣០(១)។

[50] *សូមមើល* ឯកសារលេខ D-427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ERN 00604508-00605246 ("ដីកាដំណោះស្រាយ") កថាខណ្ឌ ១៥៤០។

ផែនការ ឬ គោលបំណងរួម[51]។ សហឧក្រិដ្ឋកម្មរួមមានពីរទម្រង់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក ៖ "សហឧក្រិដ្ឋកម្មរួមទម្រង់ទី I ដែលពាក់ព័ន្ធនឹងករណីទាំងឡាយដែលអ្នកចូលរួមទាំងអស់បានធ្វើសកម្មភាពស្របទៅតាមគោលបំណងរួម និងមានចេតនាឧក្រិដ្ឋកម្មរួមដូចគ្នា [និង] សហឧក្រិដ្ឋកម្មរួមទម្រង់ទី II គឺមានលក្ខណៈជាប្រព័ន្ធ ពោលគឺសំដៅលើករណីនៃអំពើធ្វើបាបជាលក្ខណៈប្រព័ន្ធនៅក្នុងស្ថាប័នរៀបចំណាមួយ ដូចជា ជំរំប្រមូលផ្តុំជាដើម"[52]។

29. ធាតុផ្សំ*សត្យានុម័ត* (*actus reus*) នៃសហឧក្រិដ្ឋកម្មរួមទាំងពីរទម្រង់ គឺដូចគ្នា ហើយត្រូវបានអង្គជំនុំជម្រះសរសេររៀបរាប់យ៉ាងជាក់លាក់នៅក្នុងសាលដីកាខុចដូចតទៅ៖ "ទីមួយ មនុស្សច្រើន...ទីពីរ អត្ថិភាពនៃគោលបំណងរួមដែលស្មើទៅនឹង ឬ ពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែលអង្គជំនុំជម្រះមានយុត្តាធិការ...ទីបី ការចូលរួមរបស់ជនជាប់ចោទនៅក្នុងគោលបំណងរួម"[53]។ ការចូលរួមរបស់ជនជាប់ចោទត្រូវតែជា "ការចូលរួមចំណែកដ៏មានអត្ថន័យជាសំខាន់" ដល់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[54]។

30. ធាតុផ្សំ*អត្តនោម័ត* នៃសហឧក្រិដ្ឋកម្មទម្រង់ទី I គឺ "ជនជាប់ចោទត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ [ដោយគោរពទៅតាមគោលបំណងរួម] ហើយសហចារីទាំងអស់ត្រូវតែមានចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនេះផងដែរ"[55]។ ដូច្នេះ សហឧក្រិដ្ឋកម្មទម្រង់ទី I អនុវត្តនៅក្នុងករណីដែលអ្នក

---

[51] អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការប្រព្រឹត្តនៅក្នុងវិសាលភាពនៃមាត្រា ២៩(ថ្មី)នៃច្បាប់ អ.វ.ត.ក។ *សូមមើល* សំណុំរឿង ០០១ ឯកសារលេខ E-188 "សាលក្រម" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ERN 00572517-00572797 ("សាលក្រមខុច") កថាខណ្ឌ ៥៥១។ *សូមមើល* ឯកសារលេខ D-97/15/9 "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១២ ERN 00486521-00486589 កថាខណ្ឌ ៤៩។

[52] *សូមមើល* ឯកសារលេខ E-100/6 "សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋរួម" ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ERN 00741351-00741366 ("សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម") កថាខណ្ឌ ១៥។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចហើយថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III ពុំមានអត្ថិភាពនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយនៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ហេតុដូច្នេះ សហឧក្រិដ្ឋកម្មទម្រង់ទី III នេះមិនអាចអនុវត្តលើជនជាប់ចោទបានឡើយ។ *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣៨ ទំព័រ ១៦។

[53] *សូមមើល* សាលក្រមខុច កថាខណ្ឌ ៥០៨។

[54] សាលក្រមខុច កថាខណ្ឌ ៥០៨។ ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Simic* IT-95-9-T "សាលក្រម" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥៩។

[55] *សូមមើល* សាលក្រមខុច កថាខណ្ឌ ៥០៩។

ចូលរួមទាំងអស់នៅក្នុងសហឧក្រិដ្ឋកម្មរួមមានចេតនាប្រព្រឹត្ត *អំពើព្រហ្មទណ្ឌជាក់លាក់ណាមួយ* ដែលអំពើនេះគឺជាគោលបំណងនៃសហឧក្រិដ្ឋកម្មរួម[56]។ ធាតុផ្សំអត្តនោម័ត (*mens rea*) នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី II តម្រូវថា ជនជាប់ចោទបានដឹងអំពីចរិតលក្ខណៈនៃប្រព័ន្ធ [ធ្វើបាប] និងមាន[ចេតនា]ជួយជ្រោមជ្រែងប្រព័ន្ធធ្វើបាបជារួមនេះ"[57]។

<u>ii - សហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១</u>

31. លក្ខណៈសំខាន់នៃសហឧក្រិដ្ឋកម្មរួមត្រូវបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយមានខ្លឹមសារដូចខាងក្រោម៖

១៥២៤. ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យគឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជាតាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួម នេះរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។

---

[56] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Stakic IT-97-24-A "សាលដីកា" ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៥។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kvocka និងជនផ្សេងទៀត* IT-98-30/1-A "សាលដីកា" ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ ("សាលដីកា *Kvocka*") កថាខណ្ឌ ៨២។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntakirutimana និង Ntakirutimana* ICTR-96-10-A និង ICTR-96-17-A "សាលដីកា" ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤៦៧។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Vasiljevic* IT-98-32-A "សាលដីកា" ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ១០១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac* IT-97-25-A "សាលដីកា" ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ ៨៤។ រឿងក្តី Tadić កថាខណ្ឌ ១៩៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krajisnik* IT-00-39-T "សាលក្រម" ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៨៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Simba* ICTR-01-76-T "សាលក្រម" ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ៥១១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Simba* ICTR-01-76-T "សាលក្រម និងទោស" ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ កថាខណ្ឌ ៣៨៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Limaj និងជនផ្សេងទៀត* IT-03-66-T "សាលក្រម" ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ៥១១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blagojevic និង Jokic* IT-02-60-T "សាលក្រម" ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ កថាខណ្ឌ ៧០៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brdanin* IT-99-36-T "សាលក្រម" ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ២៦៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង simic, Tadić និង Zaric* IT-95-9-T "សាលក្សម" ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥៦ ១៥៧ ១៦០។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Vasiljevic* IT-98-32-T "សាលក្រម" ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ៦៤។

[57] *សូមមើល* សាលក្រមឌុច កថាខណ្ឌ ៥០៩។

១៥២៥. ដើម្បីសម្រេចបានផែនការរួមនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកំណត់យកគោលនយោបាយ ៥ យ៉ាងដូចមានរៀបរាប់ខាងក្រោម ដែលការដាក់ឲ្យអនុវត្តនូវគោលនយោបាយទាំង ៥ នេះ រួមមានជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួមនេះ[58]។

យោងតាមដីកាបំបែកកិច្ចដំណើរការនីតិវិធី គោលនយោបាយមានចំនួនតែពីរប៉ុណ្ណោះក្នុងចំណោម "គោលនយោបាយ" ទាំងប្រាំ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ រួមមាន គោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជន និងការប្រព្រឹត្តលើក្រុមគោលដៅ[59]។ ពាក់ព័ន្ធនឹងគោលនយោបាយនេះ នួន ជា ត្រូវបានចោទប្រកាន់ចំពោះ (i) ការធ្វើមនុស្សឃាត (ii) ការសម្លាប់រង្គាល (iii) ការធ្វើទុក្ខបុកម្នេញខាងនយោបាយ (iv) អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ[60]។

32. នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់សំណើសុំថា ផ្នែកនៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមគួរលុបចោលដោយហេតុថា គោលបំណងរួមដែលត្រូវបានសំអាងនៅក្នុងនោះមិនមានចរិតលក្ខណៈឧក្រិដ្ឋឡើយ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ("សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម") អង្គជំនុំជម្រះបានយល់ស្របតាមយុត្តិសាស្ត្ររបស់សាលាក្តី ICTY និងតុលាការពិសេស SCSL ថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមពុំចាំបាច់ទាល់តែមានចរិតលក្ខណៈឧក្រិដ្ឋនោះទេ ល្គឹកណាគោលបំណងនេះ "បង្កើតជា" "ពាក់ព័ន្ធនឹង" ឬ "មានចេតនាបម្រុងនឹង" ប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ បើទោះជាគោលបំណងនេះការខ្វែងយោបល់គ្នានៅក្នុងពេលបង្កើតវាក៏ដោយ[61]។ ប្រសិនបើយើងត្រឡប់មកមើលដីកាដំណោះស្រាយវិញ អង្គជំនុំជម្រះបានសម្រេចដូចបានអះអាងនៅក្នុងនោះថា "ផែនការនោះ *ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើ*

---

[58] *សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤-៥។

[59] *សូមមើល* ឯកសារលេខ E-124/7.3 "ឧបសម្ព័ន្ធ" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ ERN 00852356-00852358 ទំព័រ ៣ (ផ្នែក ៥ (ក))។

[60] *សូមមើល* ឯកសារលេខ E-124/7.3 "ឧបសម្ព័ន្ធ" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ ERN 00852356-00852358 ទំព័រ ២ (ផ្នែក ៤)។

[61] *សូមមើល* សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧។

*ឧក្រិដ្ឋបរបស់សមាជិកសហឧក្រិដ្ឋរួម'* ហេតុដូច្នេះ ផែនការនេះមានលក្ខណៈគ្រប់គ្រាន់យោងតាមយុត្តិសាស្ត្រ[62]។

<u>iii - *លក្ខខណ្ឌនៃការបង្ហាញភស្តុតាង ៖ សហឧក្រិដ្ឋកម្មទម្រង់ទី* I</u>

33. ដូចបានកត់សម្គាល់រួចមកហើយ ខ្លឹមសារនៃសហឧក្រិដ្ឋកម្មទម្រង់ទី I គឺថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ត្រូវ*ស្ថិតនៅក្នុងគោលបំណង* នៃផែនការរួម ហើយជនជាប់ចោទ *មានចេតនារួម* ជាមួយនឹងបុគ្គលដែលជាអ្នកបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះដោយផ្ទាល់[63]។ ហេតុដូច្នេះ នៅក្នុងករណីនេះ ជនជាប់ចោទអាចចាប់ឲ្យទទួលខុសត្រូវចំពោះ*ឧក្រិដ្ឋកម្មជាក់លាក់* ទាំងឡាយណាដែលស្ថិតនៅក្រោមគោលបំណងនៃផែនការរួមនេះ ហើយដែលចេតនារបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មទាំងនោះត្រូវបានបង្ហាញឲ្យឃើញ។

34. ចំពោះការសម្រេចរបស់អង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមថា ដីកាដំណោះស្រាយបានសំអាងយ៉ាងត្រឹមត្រូវថា ផែនការរួម "ពាក់ព័ន្ធនឹង" ការប្រព្រឹត្តអំពើឧក្រិដ្ឋ, ការសម្រេចនេះពុំបានផ្លាស់ប្តូរគោលការណ៍ជាមូលដ្ឋាននៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមឡើយ[64]។ ចំណុចដំបូង ពាក្យថា "ពាក់ព័ន្ធនឹង" មានលក្ខណៈស្រពិចស្រពិលចំពោះលក្ខណៈជាក់លាក់នៃទំនាក់ទំនងរវាងផែនការរួម និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជាពិសេស ចេតនារបស់ជនជាប់ចោទ។ម្យ៉ាងវិញទៀត យុត្តិសាស្ត្រដែលអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋាននៅក្នុងសេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម ពុំបានធ្វើឲ្យមានការប្រែប្រួលណាមួយចំពោះបទដ្ឋានអនុវត្តជាធរមានលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ឡើយ។ យុត្តិសាស្ត្រនោះគឺ សាលដីកានៅក្នុងរឿងក្តី *Brima* នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (តុលាការពិសេសសេរ៉ាឡេអូន) និងរឿងក្តី *Kvocka* នៅសាលាក្តី ICTY។

35. ចំណុចទីមួយ រឿងក្តីទាំងពីរនេះពុំបានអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី I ឡើយ។ នៅក្នុងរឿងក្តី

---

[62] *សូមមើល* សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៩ (គូសបញ្ជាក់បន្ថែម)។

[63] *សូមមើល* លេខយោងជើងទំព័រ XX *ខាងលើ*។

[64] ភាសានៅក្នុងដីកាដំណោះស្រាយមានលក្ខណៈពុំច្បាស់លាស់អំពីទំនាក់ទំនងរវាងផែនការរួម និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដោយអះអាងត្រឹមតែថា "*ការអនុវត្ត* [ផែនការនេះ] បណ្តាលឲ្យ និង/ឬ ពាក់ព័ន្ធនឹង" ការប្រព្រឹត្តឧក្រិដ្ឋកម្ម។ *សូមមើល សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៥។

*Brima* អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់នៅពេលខ្លួនសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមពុំត្រូវបានសំអាងឲ្យបានត្រឹមត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប៉ុន្តែបែរជាមិនបានព្យាយាមវាយតម្លៃលើការទទួលខុសត្រូវរបស់ជនជាប់ចោទក្រោយពីបានពិចារណាលើគោលបំណងរួមដូចបានចោទប្រកាន់[65]។ នៅក្នុងរឿងក្តីក្រោយមួយទៀតពាក់ព័ន្ធនឹង RUF នៅពេលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេស SCSL ពិតជាបានបង្ហាញការយល់ឃើញផ្អែកអង្គហេតុដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមនោះ អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា "ក្នុងករណីដែលការកាន់កាប់អំណាច និងការគ្រប់គ្រងលើអាជ្ញាធររដ្ឋមួយ *មានចេតនា* អនុវត្តតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានចែងនៅក្នុងលក្ខន្តិកៈ ករណីនេះអាចបង្កើតជាគោលបំណងឧក្រិដ្ឋរួមមួយបាន"[66] ហើយ "មធ្យោបាយ*ដែលមានការឯកភាពគ្នា* ដើម្បីសម្រេចគោលបំណងទាំងនេះ រួមមានការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងការរំលោភបំពាន និងការធ្វើបាបប្រជាជនជនស៊ីវិល"[67]។ ដូចគ្នានេះដែរ នៅក្នុងរឿងក្តី *Kvocka* អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី II ពុំមែន សហឧក្រិដ្ឋកម្មទម្រង់ទី I ឡើយ[68]។ នៅពេលអង្គជំនុំជម្រះបានលើកឡើងអំពីសហឧក្រិដ្ឋកម្មទម្រង់ទី I អង្គជំនុំជម្រះបានរៀបរាប់បទដ្ឋានថា "ជាករណីដែលអ្នកចូលរួមទាំងឡាយបានធ្វើសកម្មភាពទៅតាមការរៀបចំរួម

---

[65] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brima និងជនផ្សេងទៀត* SCSL-04-16-PT-006 "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ៣៤។ ក្រុមមេធាវីការពារក្តីក៏សូមកត់សម្គាល់ថា សេចក្តីសម្រេចលើរឿងក្តី *Brima* បានក្លាយជាកម្មវត្ថុនៃការរិះគន់យ៉ាងខ្លាំងនៅក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវ។ *សូមមើល* G. Boas, J.L. Bischoff និង L. Reid បណ្ណាល័យអ្នកអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ Volume I ទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ W. Jordah និង P. Van Tuyl ការបរាជ័យក្នុងការអនុវត្តបន្ទុកបង្ហាញភស្តុតាង តើសហឧក្រិដ្ឋកម្មរួមថយចុះយ៉ាងដូចម្តេចនៅតុលាការពិសេសនៅប្រទេស Sierra Leone, 606 8 J. Int'l Crim. Just. (ឆ្នាំ ២០១០) ទំព័រ ៨។ *សូមមើល*ផងដែរ J.Easterday ភាពស្មុគស្មាញនៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម : ការផ្តន្ទាទោសលើ Augustine Gbao តុលាការពិសេសនៅប្រទេស Sierra Leone Berkley J. Int'l L. Publicist 3 (ឆ្នាំ ២០០៩)។

[66] *សូមមើល*រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sesay Kallon និង Gbao* SCSL-04-15-PT-005 "សាលក្រម" ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ១៩៩២។

[67] សាលក្រម RUF កថាខណ្ឌ ១៩៨០។

[68] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kvocka និងជនផ្សេងទៀត* IT-98-30/1-T "សាលក្រម" ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ២៦៨។

ហើយដែលអ្នកទាំងអស់នេះមានចេតនាឧក្រិដ្ឋរួម"[69]។ ចំពោះអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Haradinaj* ដែលរឿងក្តីនេះជាយុត្តិសាស្ត្រតែមួយគត់ដែលតុលាការពិសេស SCSL នៅក្នុងរឿងក្តី *Brima*[70] យកមកធ្វើជាមូលដ្ឋាននោះ អង្គជំនុំជម្រះសាលាដំបូងនេះក៏បានអនុវត្តដូចគ្នាដែរ[71]។

36. ម្យ៉ាងវិញទៀត នៅក្នុងរឿងក្តី *Haradinaj* និងរឿងក្តី *Brima* គោលបំណងរួមដូចដែលបានសំអាងនោះ មានលក្ខណៈជាប់ពាក់ព័ន្ធពុំអាចបំបែកចេញពីអំពើឧក្រិដ្ឋដូចបានចោទប្រកាន់។ នៅក្នុងរឿងក្តី *Haradinaj* ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងថា គោលបំណងរួម "*ចាំបាច់ត្រូវពាក់ព័ន្ធនឹង* ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភលើច្បាប់ ឬ ទំនៀមទម្លាប់សង្គ្រាម"[72]។ ដូចគ្នានេះដែរ នៅក្នុងរឿងក្តី *Kvocka* ដូចអង្គជំនុំជម្រះក្នុងរឿងក្តីនេះបានលើកឡើងគោលបំណងរួមពុំមែនជាការបង្កើត "រដ្ឋហ្សែប៊ីនៅក្នុងអតីតប្រទេសយូហ្គោស្លាវី"[73]ទេ ប៉ុន្តែ "វាជាការបំបាត់តំបន់ព្រីជេដ័រ (Prijedor) របស់អ្នកកាន់សាសនាអ៊ីស្លាម និងជនជាតិក្រូអាងក្នុងគោលបំណងដើម្បីបង្កើតរដ្ឋហ្សែប៊ី (Serb) រួមមួយ"[74]។ នៅក្នុងករណីទាំងពីរ អំពើឧក្រិដ្ឋនេះពុំអាចបំបែកចេញពីគោលបំណងរួមឡើយ។ ករណីដូច្នេះពុំមាននៅក្នុងរឿងក្តីបច្ចុប្បន្ននោះទេ

---

[69] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Kvocka* *និងជនផ្សេងទៀត* IT-98-30/1-T "សាលក្រម" ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០១ កថាខណ្ឌ ២៦៧។

[70] ក្រៅពី *Haradinaj,* ឯកសារសំអាងដែល *Brima* បានយកមកធ្វើជាមូលដ្ឋានគឺលក្ខន្តិកៈទីក្រុងរ៉ូម។ ទោះបីជាយ៉ាងនេះក្តី តុលាការ ICC បានច្រានចោលសហឧក្រិដ្ឋកម្មរួមដែលជាមូលដ្ឋាននៃការទទួលខុសត្រូវនៅតុលាការ ICC ហើយបានបញ្ជាក់យ៉ាងច្បាស់ថា មាត្រា ២៥(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមគឺជា "ទម្រង់ដែលនៅសេសសល់នៃការទទួលខុសត្រូវរបស់អ្នកសមគំនិត" (*សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Thomas Lubanga Dyilo* ICC-01/04-01/06-8-Corr "សេចក្តីសម្រេចលើការចេញដីកាចាប់ខ្លួន" ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ កថាខណ្ឌ ៣០០-៣៤០)។ ហេតុដូច្នេះ វាពុំត្រឹមត្រូវឡើយក្នុងការយកមាត្រា ២៥(៣)នៃលក្ខន្តិកៈទីក្រុងរ៉ូម មកបកស្រាយអំពីវិសាលភាពនៃគោលបំណងរួមនោះ។

[71] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Haradinaj* *និងជនផ្សេងទៀត* IT-04-84-T "សាលក្រម" ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ១៣៨។

[72] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Haradinaj* *និងជនផ្សេងទៀត* IT-04-84 ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែជាលើកទីពីរ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ២៦។

[73] *សូមមើល* សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧ (ដកស្រង់ចេញពីកថាខណ្ឌ ៤៦ នៃ *Kvocka* *និងជនផ្សេងទៀត* សាលដីកា)។

[74] *សូមមើល* សាលដីកា *Kvocka* កថាខណ្ឌ ៤៥។ ដូចបានកត់សម្គាល់រួចហើយ នៅពេលអនុវត្តសាលដីកា *Brima* អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *RUF* បានបញ្ចូលទង្វើឧក្រិដ្ឋនៅក្នុងគោលបំណងរួម។

ដោយគោលបំណងនៃការសម្រេចបដិវត្តន៍សង្គមនិយមដ៏ឆាប់រហ័សមួយ*អាចអនុវត្ត* នៅក្នុងមធ្យោបាយមួយដែលពុំចាំបាច់មានការពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋទាល់តែសោះ[75]។

37. ហេតុដូច្នេះ ដើម្បីឱ្យស្របតាមបទដ្ឋានដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវចំពោះសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទី I ការិយាល័យសហព្រះរាជអាជ្ញាត្រូវបង្ហាញចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តនៅក្នុងឧក្រិដ្ឋកម្មនីមួយៗដែលត្រូវបានចោទប្រកាន់ ដោយពុំត្រូវគិតអំពីពាក្យពេចន៍ ឬប្រយោគនៅក្នុងនិយមន័យនៃគោលបំណងរួមនេះឡើយ។ សហព្រះរាជអាជ្ញាត្រូវបង្ហាញ (i) អត្ថិភាពនៃគោលបំណងរួមក្នុងការធ្វើបដិវត្តន៍សង្គមនិយមដ៏ឆាប់រហ័សមួយនៅក្នុងប្រទេសកម្ពុជាតាមរយៈ "ជំហានមហាលោតផ្លោះ" ដែលរួមមាន ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងទៀត (ii) ជនជាប់ចោទបានចូលរួម ពោលគឺ បានចូលរួមចំណែកដ៏មានអត្ថន័យជាសំខាន់នៅក្នុងគោលបំណងរួមនោះ (iii) ជនជាប់ចោទ*មានចេតនា* ថា ការអនុវត្តផែនការរួមនោះ*នឹងរួមបញ្ចូលទាំង* ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ និង (iv) ជនជាប់ចោទមានចេតនាជាក់លាក់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដូចបានចោទប្រកាន់ ដែលចេតនានេះគឺជាធាតុផ្សំមួយជាក់លាក់នៃឧក្រិដ្ឋកម្មនេះ។

## ឃ. ការទទួលខុសត្រូវរបស់ថ្នាក់លើ

38. មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងថា ថ្នាក់លើអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលត្រូវបានប្រព្រឹត្តដោយបុគ្គលិកក្រោមបង្គាប់របស់ខ្លួន "ប្រសិនបើថ្នាក់លើនោះអាចបញ្ជា បានគ្រប់គ្រង ឬ មានអំណាច និងមានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើបុគ្គលិកក្រោមបង្គាប់ ហើយថ្នាក់លើនោះបានដឹង ឬ មានហេតុផលអាចដឹងថាបុគ្គលិកក្រោមបង្គាប់របស់យើងហៀបនឹងប្រព្រឹត្តអំពើបែបនេះ ឬ បានប្រព្រឹត្តអំពើបែបនេះរួចមកហើយ ហើយថ្នាក់លើមិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់អំពើបែបនេះ ឬ ដើម្បីដាក់ទណ្ឌកម្មលើចារី"[76]។

---

[75] *សូមមើល* កថាខណ្ឌ XX *ខាងលើ*។

[76] អង្គជំនុំជម្រះបានលើកឡើងការទទួលខុសត្រូវរបស់ថ្នាក់លើក្នុងន័យទូទៅនៅក្នុងសាក្រម ឌុច។ *សូមមើល ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច* រឿងក្តីលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ ឯកសារលេខ E-188 "សាលក្រម" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ERN 00572517-00572797 កថាខណ្ឌ ៥៣៨-៥៤៤ ("សាលក្រមឌុច")។

## i. ការទទួលខុសត្រូវរបស់ថ្នាក់លើពុំត្រូវបានទទួលស្គាល់នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលពាក់ព័ន្ធ

39. ដូចក្រុមមេធាវីការពារក្តីផ្សេងទៀតធ្លាប់បានផ្តល់ទឡ្ហីករណ៍តវ៉ាពីមុនមករួចហើយ ការទទួលខុសត្រូវរបស់ថ្នាក់លើពុំទទួលបានឋានៈជាទំនៀមទម្លាប់នោះទេនៅក្នុងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៧ នោះ ដោយហេតុថា៖ (i) ធាតុផ្សំរបស់វាពុំត្រូវបានកំណត់ច្បាស់លាស់គ្រប់គ្រាន់នៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ (ii) ការអនុវត្តរបស់រដ្ឋពុំមានលក្ខណៈស៊ីសង្វាក់គ្នា និងពុំមានសង្គតភាព និង (iii) មាត្រា ៨៦ នៅក្នុងពិធីសារបន្ថែមទី I នៃអនុសញ្ញាទីក្រុងហ្សឺណែវពុំបានឆ្លុះបញ្ចាំងវិធានច្បាប់ទំនៀមទម្លាប់ទេ[77]។ ក្រុមមេធាវីការពារក្តីយល់ស្រប និងយកតាមទឡ្ហីករណ៍ទាំងនេះ។

40. ចំពោះភាពពុំច្បាស់លាស់នៅក្នុងនិយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[78] ក្រុមមេធាវីការពារក្តីបានកត់សម្គាល់បន្ថែមទៀតថា សូម្បីនៅក្នុងសហរដ្ឋអាមេរិក យុត្តិសាស្ត្រនៅមុនឆ្នាំ ១៩៧៥ មានភាពខុសគ្នាច្រើន ជាពិសេស ពាក់ព័ន្ធនឹងបទដ្ឋាននៃការដឹងឮជាធរមាន។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Yamashita* តុលាការកំពូលនៃសហរដ្ឋអាមេរិកបានត្រឹមតែសន្មតថា ជនជាប់ចោទ

---

[77] ឯកសារលេខ D-427/1/6 "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ERN 00617486-00617631 កថាខណ្ឌ ២៨៣-៣០២។ *សូមមើល* ឯកសារលេខ D-427/2/1 "បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ ERN 00613874-00613905 កថាខណ្ឌ ៨១-៩៤។

[78] Elies Van Sliedregt, *The Criminal Responsibility of Individuals for Violations of International Humanitarian Law*, T.M.C. Asser Press: 2003 ('Van Sliedregt, 2003') ទំព័រ ១៣៥ ("ទស្សនទានមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើដែលលេចចេញមកពីសេចក្តីសង្ខេបដ៏ចម្រូងចម្រាស់គ្នានៃសង្គ្រាមលោកលើកទីពីរ [យុត្តិសាស្ត្រ] រួមមានទិដ្ឋភាពចំនួនបី i) ទិដ្ឋភាព *មុខងារ៖* មុខតំណែងរបស់ថ្នាក់លើត្រូវរួមទាំងកាតព្វកិច្ចក្នុងការចាត់វិធានការ ii) ទិដ្ឋភាព *សតិបញ្ញា៖* ថ្នាក់លើប្រាកដជាបានដឹង ឬ គួរតែបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ និង iii) ទិដ្ឋភាព *ដំណើរការ៖* ថ្នាក់លើប្រាកដជាមិនបានចាត់វិធានការ"។ ភាពជាក់លាក់ជាងនេះគឺមានលក្ខណៈពិបាកយល់ ដោយហេតុថាភាពខុសគ្នានៅក្នុង "សេចក្តីសង្ខេបដ៏ចម្រូងចម្រាស" នៃយុត្តិសាស្ត្រ "បណ្តាលឲ្យមានភាពខុសគ្នាខ្លាំងនៅក្នុងវិសាលភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ"។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Halilovic* រឿងក្តីលេខ IT-01-48-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ កថាខណ្ឌ ៤៨ ("សាលក្រម Halilovic ") (ដែលកត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើពុំត្រូវបានបកស្រាយស៊ីសង្វាក់គ្នា និងឯកភាពគ្នានោះទេ។

បានដឹង ដោយហេតុថាឧក្រិដ្ឋកម្មទាំងឡាយមានលក្ខណៈសាហាវ និងមានលក្ខណៈទូទៅ[79]។ ផ្ទុយមកវិញ នៅក្នុងរឿងក្តី *Medina* សាលាឧទ្ធរណ៍យោធានៃសហរដ្ឋអាមេរិកបានអនុវត្តបទដ្ឋាននៃការដឹងឮជាក់ស្តែងយ៉ាងតូចចង្អៀត ដែលយោងតាមបទដ្ឋាននេះ សូម្បីតែវត្តមានរបស់ជនជាប់ចោទនៅហ្នឹងកន្លែងកើតហេតុក៏មិនគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទបានដឹងឮអំពីឧក្រិដ្ឋកម្មដូចបានចោទប្រកាន់នោះឡើយ[80]។ ទើបតែនៅក្នុងសាលាក្តី *មិនអចិន្ត្រៃយ៍* តែប៉ុណ្ណោះ ដែលនិយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើបានទទួលភាពជាក់លាក់បានគ្រប់គ្រាន់[81] ពោលគឺ ដែលជាចំណុចជាក់ស្តែងមួយដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការបញ្ជាក់និយមន័យរបស់ខ្លួនឱ្យបានច្បាស់លាស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្អែក *ទាំងស្រុង* លើយុត្តិសាស្ត្របែបនោះនៅក្នុងសាលក្រមខុច[82]។

41. ទោះបីជាដូច្នេះក្តី ឋានៈនៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងឆ្នាំ ១៩៧៥ ពុំមានភាពច្បាស់លាស់ទេ។ ដើម្បីឱ្យស្របតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍របស់ជនជាប់ចោទ (in dubio reo)* អង្គជំនុំជម្រះត្រូវសម្រេចថា ការទទួលខុសត្រូវរបស់ថ្នាក់លើពុំអាចអនុវត្តបានឡើយនៅក្នុងរឿងក្តីនេះ[83]។

ii. <u>ប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើពិតជាមានអត្ថិភាពមែននោះ ការទទួលខុសត្រូវនេះ</u>

---

[79] *សូមមើល* រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Yamashita* 327 US 1 (1946) (រឿងក្តី Yamashita)។ នៅក្នុងមតិជំទាស់ចៅក្រម Murphy បានផ្តល់ទទ្ទីករណ៍ថា សេចក្តីសម្រេចរបស់ចៅក្រមភាគច្រើនមិនបានបង្កើតជាលក្ខខណ្ឌនៃការដឹងឮទាល់តែប៉ុណ្ណោះ។ *សូមមើល ដូចខាងលើ* ទំព័រ ៣៩-៤០។

[80] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Medina,* in L. Friedman, *The Law of War. A Documentary History,* Volume II, Random House: 1972 ទំព័រ ១៧៣២។

[81] *សូមមើល ឧ.* Robert Cryer និងជនផ្សេងទៀត *សេចក្តីណែនាំអំពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* Oxford University Press: 2009 ទំព័រ ៣៨៨-៣៨៩។

[82] សាលក្រមខុច ទំព័រ ៥៣៨-៥៤៤។

[83] *សូមមើល* Antonio Cassese ed., *សម្ពហកម្មអំពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* Oxford University Press: 2009 ទំព័រ ៤៤០-៤៤១ (*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* "គឺជាគោលការណ៍មួយ [...] ដែលទាមទារលក្ខខណ្ឌថា នៅក្នុងករណីមានការបកស្រាយខ្វែងយោបល់គ្នាលើវិធានណាមួយនោះ ការបកស្រាយដោយសន្ទតនឹងបានប្រយោជន៍ទៅជនជាប់ចោទ")។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥០០-៥០១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstic* សំណុំរឿងលេខ IT-98-33-T អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥០២។

<u>ត្រូវបានកំណត់តាមនិយមន័យដែលមានលក្ខណៈរិតត្បិតតែប៉ុណ្ណោះ</u>

***ភាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការចាត់វិធានការ***

42. ក្រៅពីធាតុផ្សំទាំងបីនៃការទទួលខុសត្រូវរបស់ថ្នាក់លើដូចមានបញ្ជាក់នៅក្នុងសាលក្រមខុច[84] យុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទីពីរតម្រូវថា ថ្នាក់លើត្រូវមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការចាត់វិធានការ។ ដូចចៅក្រម Röling បានសម្រេចនៅក្នុងមតិជំទាស់របស់ខ្លួននៅក្នុងសាលក្រមរបស់សាលាក្តី IMTFE៖

> គេអាចអះអាងថា កាតព្វកិច្ចនេះកើតមានមែន ដរាបណាការដឹងឮ និងអំណាចនោះកើតមានពិតប្រាកដ។ ច្បាប់អន្តរជាតិអាចវិវឌ្ឍដល់ចំណុចនេះ។ ក៏ប៉ុន្តែ នៅក្នុងពេលបច្ចុប្បន្ន គេត្រូវពិនិត្យមើលកាតព្វកិច្ចជាក់លាក់ដែលដាក់បន្ទុកលើមន្ត្រីរដ្ឋាភិបាល និងមេបញ្ជាការយោធា ដែលនាំឲ្យ អ្នកទាំងនេះទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌចំពោះ "អំពើអកម្ម" ទាំងនេះ[85]។

43. ទស្សនៈយល់ឃើញរបស់ចៅក្រម Röling ត្រូវបានបង្ហាញថាមានលក្ខណៈត្រឹមត្រូវនៅក្នុងប្រភពសំខាន់ៗជាច្រើន។ គណៈប្រតិភូអាមេរិកដែលបានអញ្ជើញចូលរួមនៅក្នុងសន្និសីទសន្តិភាពនៅក្នុងឆ្នាំ ១៩១៩[86] តុលាការកំពូលនៃសហរដ្ឋអាមេរិកនៅក្នុងរឿងក្តី *Yamashita*[87] និង

---

[84] ធាតុផ្សំទាំងនេះឆ្លុះបញ្ចាំងនៅក្នុងនិយមន័យនៃការទទួលខុសត្រូវរបស់ថ្នាក់លើ នៅក្នុងពេលសព្វថ្ងៃ។ *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Delalic *និងជនផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ("សាលក្រម Celebici") កថាខណ្ឌ ៣៤៦ ក្រោយមកបានតម្កល់នៅក្នុងបណ្តឹងឧទ្ធរណ៍។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Delalic *និងជនផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២១៤។

[85] "មតិយោបល់របស់សមាជិកនៃប្រទេសហូឡង់ដ៏ (លោកចៅក្រម Röling) កថាខណ្ឌ ៦០ នៅក្នុង Neil Boister & Rober Cryer ed., *Dococuments on the Tokyo International Military Tribunal – Charter, Indictment and Judgments*, Oxford University Press: 2008 ទំព័រ ៧០៧ ("មតិជំទាស់របស់ចៅក្រម Röling")។

[86] របាយការណ៍បង្ហាញជូននៅក្នុងសន្និសីទសន្តិភាពបឋម ដែលរៀបចំឡើងដោយគណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកផ្តួចផ្តើមសង្គ្រាម និងស្តីពីការអនុវត្តទណ្ឌកម្ម ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩ ដកស្រង់ចេញពីមតិជំទាស់របស់ចៅក្រម Röling ទំព័រ ៧០៥ ដល់ ៧០៦ ("ដើម្បីបង្ហាញការទទួលខុសត្រូវនៅក្នុងករណីបែបនេះ...ការដឹងឮអំពីការប្រព្រឹត្ត និងលទ្ធភាពក្នុងការទប់ស្កាត់ ពុំមែនគ្រប់គ្រាន់តែឯងនោះទេ។ **ភារកិច្ច ឬ កាតព្វកិច្ចនៅក្នុងការចាត់វិធានការគឺមានភាពចាំបាច់**") (គូសបញ្ជាក់បន្ថែម)។

សាលក្រមលើបញ្ហាវេជ្ជសាស្ត្ររបស់សាលាក្តី NMT ទាំងអស់សុទ្ធតែបានយល់ឃើញថា កាតព្វកិច្ចផ្លូវច្បាប់ក្នុងការចាត់វិធានការគឺជាលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ថ្នាក់លើ[88]។ ម្យ៉ាងវិញទៀត វាជាគោលការណ៍ទូទៅនៃច្បាប់ ដែលថា ការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើអកម្មកើតមាននៅពេលកាតព្វកិច្ចនៅក្នុងការចាត់វិធានការដោះស្រាយមានអត្ថិភាព អាចអនុវត្តបានតាមរយៈក្រម ព្រហ្មទណ្ឌក្នុងប្រទេស និងត្រូវបាន "ដឹងឮ និងផ្សព្វផ្សាយជាសាធារណៈ" តែប៉ុណ្ណោះ[89]។ អាស្រ័យហេតុនេះ លក្ខខណ្ឌនេះត្រូវបានទទួលស្គាល់នៅក្នុងសាលាក្តី ICTR[90] និងតុលាការ ICC[91] ជាទិដ្ឋភាពមួយ នៃការទទួលខុសត្រូវ របស់

---

[87] *សូមមើល Yamashita* ទំព័រ ១៤ ដល់ ១៥ (ដោយត្រូវពិចារណាថាតើ "ច្បាប់នៃសង្គ្រាមដែលបានបញ្ញត្តិលើមេបញ្ជាការយោធាអំពីភារកិច្ចក្នុងការចាត់វិធានការសមស្រប គឺស្ថិតនៅក្រោមអំណាចរបស់មេបញ្ជាការនេះក្នុងការគ្រប់គ្រងទាហានរបស់ខ្លួនដែរឬទេ", ទំព័រ ៤៣ ដល់ ៤៤ (ចៅក្រម Rutlege មតិជំទាស់៖ ការទទួលខុសត្រូវទាមទារឱ្យជនជាប់ចោទ "ខកខានដោយចេតនានៅក្នុងការចាត់វិធានការទប់ស្កាត់ការប្រព្រឹត្តខុសធ្វើឡើងដោយអ្នកផ្សេង នៅពេលដែលខ្លួនមានភារកិច្ច និងអំណាចអាចចាត់វិធានការបាន")។

[88] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Karl Brandt និងជនផ្សេងទៀត* សំណុំរឿងលេខ ១ "សាលក្រម" នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuremberg Volume II ទំព័រ ១៨៣ ដល់ ១៨៤, ២១២ ដល់ ២១៣។

[89] Alexander Zahar & Göran Sluiter, *International Criminal Law,* Oxford University Press: 2008 ទំព័រ ២៥៩ ("Alexander Zahar & Göran Sluiter")។ *សូមមើលផងដែរ* មតិជំទាស់របស់ចៅក្រម Röling ទំព័រ ៧០៤ ("ការទទួលខុសត្រូវចំពោះ "អំពើអកម្ម" គឺមានលក្ខណៈវិតត្បិតណាស់នៅក្នុងច្បាប់ក្នុងស្រុកដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីពិសេសដែលកាតព្វកិច្ចផ្លូវច្បាប់ត្រូវបានបញ្ជាក់យ៉ាងច្បាស់")។

[90] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mpambara* សំណុំរឿងលេខ ICTR-01-65-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ២៥ កថាខណ្ឌ ២៧ ("ការទទួលខុសត្រូវចំពោះការខកខានក្នុងការបំពេញកាតព្វកិច្ចទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ទាមទារឱ្យបង្ហាញភស្តុតាងថា៖ (i) ជនជាប់ចោទ *ជាប់កាតព្វកិច្ចផ្លូវច្បាប់ជាក់លាក់មួយក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម* (ii) ជនជាប់ចោទបានដឹង និងបានបដិសេធដោយចេតនាក្នុងការបំពេញកាតព្វកិច្ចផ្លូវច្បាប់")។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Rutaganira និងជនផ្សេងទៀត* សំណុំរឿងលេខ ICTR-95-1C-T "សាលក្រម និងការដាក់ទោស" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៧ ដល់ ៩១។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ntagaerura និងជនផ្សេងទៀត* សំណុំរឿងលេខ ICTR-99-46-T "សាលក្រម" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៥៩ ដល់ ៦៦០។ សាលាក្តី ICTY បានសម្រេចទូទៅជាងនេះថា ការទទួលខុសត្រូវចំពោះអំពើអកម្មទាមទារលក្ខខណ្ឌនៃកាតព្វកិច្ចក្នុងការចាត់វិធានការ។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaskic* IT-95-14-A "សាលដីកា" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៦៦៣។

[91] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba Gombo* សំណុំរឿងលេខ ICC-01/05-01/08 "សេចក្តីសម្រេចអនុលោមតាម មាត្រា ៦១(៧)(ក) និង(ខ)នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីបទចោទដែលរដ្ឋអាជ្ញាដាក់បន្ទុកប្រឆាំងនឹង Jean-Pierre Bemba Gombo

ថ្នាក់លើ។

44. ទោះបីជាកាតព្វកិច្ចផ្លូវច្បាប់របស់មេបញ្ជាការយោធាក្នុងការទប់ស្កាត់ និងដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តដោយបុគ្គលិកក្រោមបង្គាប់ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក៏ដោយ "ក៏វាពុំសូវមានលក្ខណៈច្បាស់លាស់ថាតើ...ថ្នាក់លើដែលជាជនស៊ីវិល ក៏ទទួលរងនូវផលប៉ះពាល់ដោយកាតព្វកិច្ចនេះផងដែរ ឬក៏យ៉ាងណា នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន... ហើយ ប្រសិនបើប៉ះពាល់មែននោះ តើតាមរយៈហេតុផលអ្វីខ្លះ"[92]? ដោយសន្មត សម្រាប់ហេតុផលនេះ ចៅក្រម Röling បានផ្តល់ទឡ្ហីករណ៍ថា "ការទទួលខុសត្រូវចំពោះការមិនបានទប់ស្កាត់ការរំលោភលើវិធានសង្គ្រាមនោះ គួរត្រូវបានកម្រិតត្រឹមមន្ត្រីទាំងអស់នេះ ជាពិសេសដូចបានចែងបញ្ជាក់នៅក្នុងច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធ"[93]។

45. ក្រមព្រហ្មទណ្ឌកម្ពុជាពុំបានចែងអំពីការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងពេលដែលពាក់ព័ន្ធនេះទេ[94]។ ហេតុនេះ ការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តបានចំពោះថ្នាក់លើដែលពុំមែនជាយោធាឡើយ លើកលែងតែកាតព្វកិច្ចក្នុងការប្រព្រឹត្តត្រូវបានគេកំណត់នៅក្នុងច្បាប់ក្នុងស្រុកនៅពេលមានកាតព្វកិច្ចបែបនោះ។

***ថ្នាក់លើដែលពុំមែនជាយោធា***

46. ប្រសិនបើកាតព្វកិច្ចរបស់ថ្នាក់លើដែលពុំមែនជាយោធាក្នុងការចាត់វិធានការ អាចត្រូវរកឃើញថាបានចែងមែននោះ ក៏ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើគួរត្រូវបានអនុវត្តបានយ៉ាងរិតត្បិតចំពោះថ្នាក់លើប្រភេទនេះដដែល[95] ពោលគឺថ្នាក់លើប្រភេទនេះគួរចាប់ឲ្យទទួលខុសត្រូវតែ "ត្រឹម

---

កថាខណ្ឌ ៤០៥ ដកស្រង់ចេញពីសាលក្រម Celebici កថាខណ្ឌ ៣៣៤ (ការទទួលខុសត្រូវរបស់ថ្នាក់លើអាចយល់បានប្រសើរបំផុតតាមរយៈ "គោលការណ៍ដែលលើកឡើងថា ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើអកម្មកើតឡើងតែនៅពេលដែលកើតមានអត្ថិភាពនៃកាតព្វកិច្ចតាមផ្លូវច្បាប់នៅក្នុងការចាត់វិធានការ")។

[92] Alexander Zahar & Göran Sluiter ទំព័រ ២៦០។

[93] មតិជំទាស់របស់ចៅក្រម Röling ទំព័រ ៧០៧។

[94] ឯកសារលេខ D-427/1/6 "បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ" ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ERN 00617486-00617631 កថាខណ្ឌ ២៩៣។

[95] សាលក្រម *Akayesu* បានសម្រេចថា "ការអនុវត្ត [បញ្ញារបស់ថ្នាក់លើ] ទៅលើជនស៊ីវិលនៅតែមាន*ភាពចម្រូងចម្រាស*"។ អង្គជំនុំជម្រះបានផ្អែកលើមតិជំទាស់របស់ចៅក្រម Röling នៅក្នុងករណីនេះថា៖ "សាលាក្តីគួរមានការប្រុងប្រយ័ត្នបំផុតនៅ

កម្រិតដែលពួកគេអនុវត្តការគ្រប់គ្រងលើបុគ្គលិកក្រោមបង្គាប់របស់ខ្លួន ប៉ុណ្ណោះ...ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកម្រិតគ្រប់គ្រងរបស់មេបញ្ជាការយោធាដូចគ្នាដែរ”[96]។

***ភាពនៅដាច់ឆ្ងាយ***

47. ការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងអំឡុងពេលពាក់ព័ន្ធ ត្រូវបានអនុវត្តតែចំពោះទង្វើរបស់ *បុគ្គលិកក្រោមបង្គាប់ផ្ទាល់* តែប៉ុណ្ណោះ។ រឿងក្តីសំខាន់ៗនៅក្រោយសង្គ្រាមលោកលើកទីពីរដែលចោទប្រកាន់អំពីការទទួលខុសត្រូវរបស់ថ្នាក់លើ មានការជាប់ទាក់ទងទៅនឹងការទទួលខុសត្រូវចំពោះទង្វើរបស់បុគ្គលិកក្រោមបង្គាប់ផ្ទាល់របស់ជនជាប់ចោទ[97]។ ទស្សនាទាននៃការទទួលខុសត្រូវរបស់ថ្នាក់លើតាមរយៈអន្តរការី ពុំត្រូវបានទទួលស្គាល់ឡើយ[98]។ ការអនុវត្តរបស់រដ្ឋនៅក្នុងអំឡុងពេលពាក់ព័ន្ធក៏បានផ្តល់ការគាំទ្រតិចតួច ឬ គ្មានទាល់តែសោះចំពោះការទទួលខុសត្រូវបែប

---

ក្នុងការចាប់ឲ្យមន្ត្រីស៊ីវិលរបស់រដ្ឋាភិបាលទទួលខុសត្រូវលើទង្វើរបស់ទាហាននៅក្នុងសមរភូមិ។ ម្យ៉ាងវិញទៀត សាលាក្តីត្រូវអនុវត្តគោលការណ៍ទូទៅនៃច្បាប់ដែលមានស្រាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះ “អំពើអកម្ម””។...ការទទួលខុសត្រូវនេះគួរត្រូវបានទទួលស្គាល់នៅក្នុងន័យចង្អៀតបំផុតមួយ”។ (រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៩០ ដល់ ៤៩១)។

[96] *សូមមើល* សាលក្រម Celebici កថាខណ្ឌ ៣៧៨ និង Alexander Zahar & Göran Sluiter ទំព័រ ២៦៥ (“សញ្ញាណគតិយុត្តនៃការគ្រប់គ្រងដោយប្រសិទ្ធភាពទាមទារឲ្យបង្ហាញភស្តុតាងថា ជនជាប់ចោទជាសមាជិកនៃក្រុមបុគ្គលដែលមានគោលបំណងពេញលេញនៅក្នុងទម្រង់ជាអង្គភាពដែលមានឋានានុក្រមមួយ, ខ្សែសង្វាក់នៃការបញ្ជា និងការអនុវត្តក្នុងការចេញ និងគោរពបញ្ជាត្រូវបានទទួលស្គាល់ជាទូទៅថាមានកើតមានដូច្នេះមែន, បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ថាជាបុគ្គលិកក្រោមបង្គាប់របស់ជនជាប់ចោទបានដឹងថា ការមិនគោរពតាម ឬ ការរឹងរូសណាមួយអាចបណ្តាលឲ្យមានការដាក់ទណ្ឌកម្មវិន័យ ហើយថ្នាក់លើមានមធ្យោបាយក្នុងការបង្រ្កាប ឬដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពលើសកម្មភាពទាំងឡាយណាដែលពុំត្រូវបានអនុញ្ញាតឲ្យបំពេញ”។

[97] *សូមមើល ឧ.* Yamashita។ រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Oswald Pohl និងជនផ្សេងទៀត* សំណុំរឿងលេខ ៤ “សាលក្រម” នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាNuremberg Volume V។ រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Wilhelm Von Leeb និងជនផ្សេងទៀត* សំណុំរឿងលេខ ១២ “សាលក្រម” នៅក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាNuremberg Volume XI។ រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Wilhelm Von Leeb និងជនផ្សេងទៀត* សំណុំរឿងលេខ ៧ “សាលក្រម” នៅក្នុងចំណុច*ដូចខាងលើ*។

[98] Van Sliedregt 2012 ទំព័រ ១៩៤។ Guenael Mettrauz, *The Law on Command Responsibility,* Oxford University Press: 2009 ទំព័រ ១៣៥ ដល់ ១៣៦ (“Mettraux”)។

នេះ ក្នុងលក្ខណៈស្រដៀងគ្នា[99]។

48. Van Sliedregt បានផ្តល់ទឡ្ហីករណ៍ថា ការទទួលខុសត្រូវរបស់ថ្នាក់លើគួរតែត្រូវអនុវត្ត តែក្នុងករណីដែលថា៖

> ដរាបណាថ្នាក់លើមានការប្រព្រឹត្តដែលគួរមានទោស ដែលអាចភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មរបស់ បុគ្គលិកក្រោមបង្គាប់។ ការទទួលខុសត្រូវចំពោះអំពើអកម្ម តាមលក្ខណៈរបស់វាមានការពិបាកនៅក្នុងការវិតក្កិតណាស់ ពីព្រោះតែបញ្ហា "ទំនាក់ទំនងហេតុ និងបច្ច័យជាសម្មតិកម្ម"។ តាមធម្មតា វាគ្មានទំនាក់ទំនងហេតុ និងបច្ច័យឡើយ។ អាស្រ័យ ទៅតាមការយល់ឃើញ គេត្រូវបង្ហាញថា តើបុគ្គលម្នាក់អាចទំនងជាបានទប់ស្កាត់អ្វីខ្លះ ប្រសិនបើបុគ្គលនេះបានធ្វើ អន្តរាគមន៍នោះ។ ហេតុផលបែបនេះមានហានិភ័យនៅក្នុងការពង្រីកការទទួលខុសត្រូវ [ដែល] វាកាន់តែជាប់ទាក់ទងទៅនឹងចំណងទាក់ទងកាន់តែច្រើនជាមួយនឹងការទទួលខុសត្រូវលើអំពើ អកម្ម[100]។

49. យោងតាមហេតុផលទាំងនេះហើយ អង្គជំនុំជម្រះគួរអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើតែចំពោះទង្វើរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់តែប៉ុណ្ណោះ[101]។

---

[99] *សូមមើល* Mettraux ទំព័រ ១៣៥។ Van Sliedregt 2012 ទំព័រ ១៩៤។ សាលាក្តី ICTY ក៏បានបង្ហាញខបញ្ញត្តិរក្សាសិទ្ធិនៅក្នុងករណីនេះ។ *សូមមើល* សាលក្រម Celebici កថាខណ្ឌ ៣៧៧ ("ការយកចិត្តទុកដាក់ខ្ពស់ត្រូវធ្វើឡើង នៅក្នុងករណីដែលភាពអយុត្តិធម៌បានប្រព្រឹត្តឡើង នៅក្នុងការចាប់បុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះសកម្មភាពរបស់បុគ្គលដទៃនៅពេលគ្មានស្ថានភាពដែលទំនាក់ទំនងរវាងការគ្រប់គ្រង ឬ នៅឆ្ងាយពីស្ថានភាពនោះពេក")។

[100] Van Sliedregt 2012 ទំព័រ ១៩៤។

[101] អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់សាលាក្តី ICTY បានទទួលស្គាល់ដោយប្រយោលអំពីទស្សនាទាននៃការទទួលខុសត្រូវរបស់ថ្នាក់លើច្រើននាក់នៅក្នុងរឿងក្តី *Oric*។ (*រដ្ឋអាជ្ញា ទល់នឹង Oric* សំណុំរឿងលេខ IT-03-68-A "សាលដីកា" ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌ ២០)។ ក្រៅពីករណីដែលថា យុត្តិសាស្ត្រនៃសាលាក្តី ICTY ពុំបានបង្ហាញការទទួលខុសត្រូវគិតចាប់ពីឆ្នាំ ១៩៧៥ សេចក្តីសម្រេចត្រូវបានរិះគន់ដោយសារវាពុំទទួលបានការគាំទ្រពីច្បាប់ទំនៀមទម្លាប់ ទោះបីជាច្បាប់នេះមានអត្ថិភាពនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ក៏ដោយ។ *សូមមើល* Van Sliedregt 2012 ទំព័រ ១៩៤។ Mettraux ទំព័រ ១៣៥ ដល់ ១៣៦។

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ**

Victor KOPPE